**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciencess Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការលុបចោលកិច្ចសន្យា

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. យិម ស៊ាវឡាំ**

សាស្ត្រាចារ្យណែនាំ

លោក **គង់ សុភ័ក្ត្រ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ យិប ស៊ាវឡាំ ជានិស្សិតថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ ជំនាន់ទី២០ ក្នុងឆ្នាំសិក្សា ២០១៩-២០២០ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមថ្លែងនូវកតញ្ញូ ដឹងគុណយ៉ាងជ្រាលជ្រៅដល់អ្នកមានគុណទាំងពីរដែលបានចិញ្ចឹមបីបាច់កូនទាំងពីតូចរហូតដល់ធំពេញវ័យ ព្រមទាំងបានផ្តល់នូវដំបូន្មានប្រៀនប្រដៅ និងបានទំនុកបម្រុងឲ្យកូនបានចូលសាលាដើម្បីក្រេបយកចំណេះដឹងទាំងពីថ្នាក់បឋម រហូតដល់ថ្នាក់បរិញ្ញាបត្រ ព្រមទាំងបានជួយជ្រោមជ្រែងសព្វបែបយ៉ាងទាំងផ្នែកសារតី និងថវិកា ដើម្បីទុកជាប្រទីបបំភ្លឺអនាគតរបស់នាង។

នាងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និងលោក/លោកស្រី សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលលោកគ្រប់រូបបានយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀន និងផ្តល់នូវចំណេះដឹងជាច្រើន ព្រមទាំងអប់រំសីលធម៌ សុជីវធម៌ ដល់នាងខ្ញុំ ដើម្បីប្រើប្រាស់ក្នុងការប្រកបការងារ ក៏ដូចជាការរស់នៅក្នុងជីវភាពប្រចាំថ្ងៃប្រកបទៅដោយសេចក្តីថ្លៃថ្នូរ ។

ជាពិសេសជាងនេះទៅទៀត នាងខ្ញុំសូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យ **គង់ សុភ័ក្រ្ត** ដែលមិនត្រឹមតែបានបង្ហាត់បង្រៀននាងខ្ញុំទេ ថែមទាំងបានណែនាំដល់នាងខ្ញុំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ និងបានចំណាយពេលវេលាមានតម្លៃ ផ្តល់ជាមតិយោបល់ ក៏ដូចជាកែសម្រួលនូវចំណុចខ្វះខាត ក្នុងការចងក្រងបង្កើតជាសារណាមួយក្បាលនេះ។

ជាទីបញ្ចប់នាងខ្ញុំសូមគោរពជូនពរ**អ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ លោក/លោកស្រីសាស្ត្រាចារ្យ**ជាទីគោរពនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ សូមឲ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពល្អបរិបូណ៌ ជន្មានយុឃឺនយូរ មានកម្លាំងពលំខ្លាំងក្លា ជាពិសេសសូមឲ្យទទួលបានភាពជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាប័ត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរយៈពេលបួនឆ្នាំរួចមក នាងខ្ញុំបានទទួលបាននូវចំណេះដឹងខាងផ្នែកទ្រឹស្តីនៃមុខវិជ្ជានីតិសាស្ត្រជាច្រើន ព្រមទាំងការលើកឡើងនូវឧទាហរណ៍នានាដែលផ្សាភ្ជាប់ក្នុងសង្គម រួមទាំងឧទាហរណ៍ដែលកើតមានឡើងក្នុងសង្គមជាក់ស្តែងពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ។ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ នាងខ្ញុំបានរៀបចំសរសេរសារណាបញ្ចប់ការសិក្សាមួយក្រោមប្រធានបទ **«ការលុបចោលកិច្ចសន្យា»** ទុកជាសក្ខីកម្មនៃចំណេះដឹងរបស់នាងខ្ញុំ។

ការលុបចោលកិច្ចសន្យា គឺមានសារៈសំខាន់ក្នុងទំនាក់ទំនងជួញដូរក្នុងជីវភាពប្រចាំថ្ងៃ ព្រោះនៅពេលដែលកិច្ចសន្យាមួយត្រូវបានបង្កើតឡើង ភាគីនៃកិច្ចសន្យាត្រូវចងដោយអត្ថន័យនៃកិច្ចសន្យានោះ ពោលគឺមានសិទ្ធិ និងកាតព្វកិច្ចត្រូវតែអនុវត្ត។ ស្របទៅតាមបរិបទនៃសង្គមបច្ចុប្បន្ន ការបង្កើតកិច្ចសន្យាគឺកើតមានឡើងជាប្រចាំថ្ងៃ សម្រាប់បម្រើឲ្យគ្រប់វិស័យទាំងអស់ រួមទាំងជំនួញជួញដូរតូចធំគ្រប់ប្រភេទ ប្រៀបដូចជាសរសៃដែលធ្វើឲ្យសេដ្ឋកិច្ចមានដំណើរ ព្រមទាំងជាចំណែកធ្វើឲ្យសង្គមជាតិរីកចម្រើន។ ប៉ុន្តែទោះបីជាកិច្ចសន្យាបានបង្កើតរួចហើយក៏ដោយ ក្នុងករណីចាំបាច់មួយចំនួន ចាំបាច់ត្រូវបដិសេធលើអានុភាពនៃកិច្ចសន្យា។ ការលុបចោលកិច្ចសន្យា ជាវិធីមួយដែលភាគីអាចបដិសេធការអនុវត្តកិច្ចសន្យា កាលណាកិច្ចសន្យានោះមានវិការៈ ឬ មូលហេតុដែលអាចលុបចោលបាន។ ទោះបីជាក្រមរដ្ឋប្បវេណីអនុញ្ញាតឲ្យភាគីអាចលុបចោលកិច្ចសន្យាពិតប្រាកដមែន ប៉ុន្តែភាគីមិនមែនចេះតែលុបចោលកិច្ចសន្យាបានតាមតែអំពើចិត្តនោះទេ លុះត្រាតែមានមូលហេតុនៃការលុបចោលដែលបានកំណត់ច្បាស់លាស់ទើបអាចលុបចោលកិច្ចសន្យាបាន។ ម្យ៉ាងវិញទៀត ការលុបចោលកិច្ចសន្យា បញ្ញត្តិឡើងដើម្បីការពារផលប្រយោជន៍របស់ភាគីនៃកិច្ចសន្យា ព្រមទាំងធានាឲ្យមានសមភាព ស្របទៅតាមគោលការណ៍នៃភាពសុចរិត និងស្មោះត្រង់។

នាងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សាមួយនេះនឹងក្លាយជាឯកសារដែលផ្តល់សារៈសំខាន់ដល់ការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត ជំនាន់ក្រោយ ព្រមទាំងអ្នកសិក្សាស្រាវជ្រាវដទៃទៀត ក្នុងការយល់ដឹង និងចែករំលាយឲ្យកាន់តែទូលំទូលាយ។

ជាចុងក្រោយ ដោយសារតែចំណេះដឹងជាមូលដ្ឋាន ការសិក្សាស្រាវជ្រាវបន្ថែម និងការសរសេររៀបចំសារណារបស់នាងខ្ញុំនៅមានកម្រិត សារណាមួយនេះនឹងមិនមានភាពល្អឥតខ្ចោះទេ ធ្វើឲ្យមានចំណុចខ្វះខាតមួយចំនួន ដូចជា អត្ថន័យ ពាក្យពេចន៍ នឹងត្រង់អក្ខរាវិរុទ្ធត្រង់កន្លែងណាមួយជាក់ជាមិនខាន។ នាងខ្ញុំរីករាយនឹងទទួលយកនូវការផ្តល់យោបល់បន្ថែម ការរិះគន់ដើម្បីស្ថាបនាពីសំណាក់សាស្ត្រាចារ្យ រៀមច្បង អ្នកសិក្សាស្រាវជ្រាវ និងមិត្តអ្នកអានគ្រប់រូបដោយក្តីសោមនស្ស ដើម្បីកែលម្អស្នាដៃមួយនេះឲ្យកាន់តែប្រសើរឡើង។

# មាតិកា

**សេចក្តីផ្តើម** ........................................................................................................ ១

## ជំពូកទី១

## លក្ខខណ្ឌនៃការលុបចោលកិច្ចសន្យា

**១.១.និយមន័យ**........................................................................................................ ៣

**១.១.១.និយមន័យ«ការលុបចោល»**........................................................................ ៣

**១.១.២. និយមន័យ «កិច្ចសន្យា»**............................................................................ ៣

**១.២.មូលហេតុនៃការលុបចោលកិច្ចសន្យា** ...........................................................................៤

**១.២.១.ករណីជនដែលខ្វះសមត្ថភាពខាងឆន្ទៈ**...........................................................................៤

**១.២.២.ករណីជនដែលខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព** ..........................................៤

១.២.២.១.អនីតិជន ...........................................................................................៥

១.២.២.២.ជននៅក្រោមអាណាព្យាបាលទូទៅ .............................................................. ៧

១.២.២.៣.ជននៅក្រោមហិតូបត្ថម្ភ ..................................................................................៩

**១.២.៣.ករណីវិការៈនៃការបង្ហាញឆន្ទៈ**........................................................................... ១០

១.២.៣.១.ការភាន់ច្រឡំ ................................................................................ ១១

ក.ការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា ..................................................... ១១

ខ.ការភាន់ច្រឡំចំណុចសំខាន់របស់ភាគី..........................................................១២

គ.ការភាន់ច្រឡំរួមគ្នា ........................................................................................១៣

១.២.៣.២.ការឆបោក................................................................................................. ១៤

ក.ការឆបោកដោយភាគីនៃកិច្ចសន្យា................................................................. ១៥

ខ.ការឆបោកដោយតតិយជន ............................................................................ ១៥

១.២.៣.៣.ពត៌មានមិនពិត.......................................................................................... ១៦

១.២.៣.៤.ការរំលោភបំពានលើស្ថានភាព.....................................................................១៧

១.២.៣.៥.ការគម្រាមកំហែង .................................................................................... ១៨

១.២.៣.៦.ការកេងចំណេញហួសហេតុ.......................................................................... ១៩

១.២.៣.៥.ការគម្រាមកំហែង .................................................................................... ១៨

១.២.៣.៦.ការកេងចំណេញហួសហេតុ.......................................................................... ១៩

## ជំពូកទី២
## វិធីនៃការលុបចោលកិច្ចសន្យា

**២.១.អ្នកមានសិទ្ធិលុបចោល** ........ ២១
**២.១.១.អ្នកមានសិទ្ធិលុបចោលករណីកិច្ចសន្យាមានវិការៈ** ........ ២១
**២.១.២.អ្នកមានសិទ្ធិលុបចោលករណីកិច្ចសន្យាធ្វើឡើងដោយខ្វះសមត្ថភាព** ........ ២២
**២.២.វិធីនៃការលុបចោលកិច្ចសន្យា** ........ ២៣
**២.៣.អាជ្ញាយុកាលនៃការរលត់សិទ្ធិលុបចោល** ........ ២៤
**២.៣.១.និយមន័យនៃអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល** ........ ២៤
**២.៣.២.លក្ខខណ្ឌនៃអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល** ........ ២៥
២.៣.២.១.ករណីបានដឹង ........ ២៥
២.៣.២.២.ករណីមិនបានដឹង ........ ២៥

## ជំពូកទី៣
## អនុភាពនៃការលុបចោលកិច្ចសន្យា

**៣.១.អានុភាពនៃការលុបចោលចំពោះភាគី** ........ ២៧
**៣.១.១.ករណីដែលភាគីមិនទាន់អនុវត្តកិច្ចសន្យា** ........ ២៧
**៣.១.អានុភាពនៃការលុបចោលចំពោះភាគី** ........ ២៧
**៣.១.១.ករណីដែលភាគីមិនទាន់អនុវត្តកិច្ចសន្យា** ........ ២៧
**៣.១.២.ករណីដែលភាគីបានអនុវត្តកិច្ចសន្យា** ........ ២៨
**៣.២.អានុភាពនៃការលុបចោលចំពោះតតិយជន** ........ ២៩
**៣.២.១.តតិយជនមុនការលុបចោល** ........ ៣០
៣.៣.១.១.ករណីវិការៈនៃការបង្ហាញឆន្ទៈ ........ ៣០
ក.ករណីកាភាន់ច្រឡំ ការឆបោក ពត៌មានមិនពិត ការរំលោភលើស្ថានភាព ........ ៣០
ខ.ករណីគម្រាមកំហែង និងកេងយកចំណេញហួសហេតុ ........ ៣១
៣.៣.១.១.ករណីវិការៈនៃការបង្ហាញឆន្ទៈ ........ ៣២
**៣.២.១.តតិយជនមុនការលុបចោល** ........ ៣២
៣.៣.២.១ ករណីចលនវត្ថុ ........ ៣៣
៣.៣.២.១ ករណីចលនវត្ថុ ........ ៣៤

**សេចក្តីសន្និដ្ឋាន** ........................................................................................................ ៣៧
**អនុសាសន៍** ............................................................................................................... ៣៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នៅក្នុងជីវភាពរបស់ប្រចាំថ្ងៃតែងតែមានទំនាក់ទំនងគតិយុត្តិក្នុងជំនួញជួញដូរ ដែលបង្កើតឲ្យមាននូវកិច្ចសន្យាជាច្រើន។ គ្រប់បុគ្គលឯកជនអាចបង្កើតកិច្ចសន្យាស្របទៅតាមឆន្ទៈរបស់ខ្លួន និងអនុវត្តកាតព្វកិច្ចផ្អែកទៅតាមការព្រមព្រៀង ដោយរដ្ឋមិនធ្វើការជ្រៀតជ្រែកទៅក្នុងទំនាក់ទំនងគតិយុត្តិរបស់បុគ្គលឯកជនទេ។ ទោះបីជាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ កំណត់នូវគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនក៏ពិតមែន ដោយផ្តល់សិទ្ធិឲ្យភាគីនៃកិច្ចសន្យាអាចកំណត់ខ្លឹមសារនៃកិច្ចសន្យា ប៉ុន្តែក៏បានភ្ជាប់នូវគោលការណ៍នៃភាពសុចរិត និងស្មោះត្រង់ជាមួយគ្នាផងដែរ ពោលគឺភាគីនៃកិច្ចសន្យាគឺត្រូវតែមានភាពស្មោះត្រង់ និងសុចរិតដើម្បីធានាឲ្យមានទាំងសេរីភាពក្នុងការបង្កើតកិច្ចសន្យា និងសមភាពនៅក្នុងកិច្ចសន្យា។ ម៉្យាងដោយសារតែប្រទេសកម្ពុជាយើងជាប្រទេសដែលកំពុងអភិវឌ្ឍន៍ ដូចនេះការយល់ដឹងអំពីច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិត ហេតុនេះហើយនៅពេលដែលពួកគាត់បានបង្កើតកិច្ចសន្យា ពួកគាត់គឺតែងតែអនុវត្តតាមវិធានទំនៀមទំលាប់ ហើយបង្កើតឲ្យកើតមានបញ្ហាជាញឹកញាប់ ព្រមទាំងមិនមានសមភាព រវាងភាគីនៃកិច្ចសន្យា លើកលែងតែអ្នកវិនិយោគទុន អ្នកជំនួញ ឬ អ្នកប្រកបអាជីវកម្មធំៗ ដែលពួកគាត់មានអ្នកប្រឹក្សាយោបល់ផ្នែកច្បាប់ សម្រាប់ប្រឹក្សានៅពេលដែលបង្កើតកិច្ចសន្យា ដើម្បីចៀសវាងការខាតប្រយោជន៍ ឬប៉ះពាល់ធ្ងន់ធ្ងរដល់មុខជំនួញរបស់ខ្លួន។ កិច្ចសន្យាដែលកើតមានជាញឹកញាប់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា មានដូចជា កិច្ចសន្យាលក់ទិញ កិច្ចសន្យាអាណត្តិ កិច្ចសន្យាខ្ចីប្រើ ភតិសន្យា កិច្ចសន្យាការងារ កិច្ចសន្យាម៉ៅការ កិច្ចសន្យាខ្ចីបរិភោគជាដើម។ ជាគោលការណ៍ក្នុងការបង្កើតសន្យា គឺកិច្ចសន្យាមួយមានអនុភាពនៅពេលដែលសំណើ និងស្នើការត្រូវគ្នា ប៉ុន្តែចំពោះកិច្ចសន្យាដែលមានការផ្ទេរអចលនវត្ថុ គឺតម្រូវឲ្យមានការធ្វើលិខិតយថាភូតបន្ថែមទៀត ទើបកិច្ចសន្យានោះមានអានុភាព។ នៅពេលដែលកិច្ចសន្យាមានអានុភាព បង្កើតឲ្យមានទំនាក់ទំនងគតិយុត្ត ដោយភាគីនៃកិច្ចសន្យាត្រូវតែអនុវត្តករណីយកិច្ចដែលមាននៅក្នុងកិច្ចសន្យានោះ ដោយមិនអាចប្រកែកបាន។ ប៉ុន្តែក្នុងករណីខ្លះភាគីនៃកិច្ចសន្យាអាចបដិសេធការអនុវត្តកិច្ចសន្យានោះបាន ដោយសារតែកិច្ចសន្យានោះមានមោឃភាព ឬជាកិច្ចសន្យាដែលមានមូលហេតុនៃការលុបចោល។ ចំពោះកិច្ចសន្យាដែលមានការលុបចោលគឺកិច្ចសន្យានោះនៅតែមានអានុភាព ដរាបណាអ្នកដែលមានសិទ្ធិលុបចោលមិនបានលុបចោលកិច្ចសន្យានោះ។ ដូច្នោះហើយក្នុងករណីដែលកិច្ចសន្យានោះ ត្រូវបានអ្នកដែលមានសិទ្ធិលុបចោលបានលុបចោល តើដំណាក់កាលណាដែលគេអាចប្រកាសការលុបចោល? តើអ្នកណាខ្លះមានសិទ្ធិលើកឡើងពីការលុបចោល ឬ ផ្តល់សច្ចានុមតិ? តើអនុភាពនៃការលុបចោល មានអនុភាពយ៉ាងណាខ្លះ ចំពោះភាគីនៃកិច្ចសន្យា? ហើយតើការលុបចោលនេះមានអានុភាពចំពោះតតិយជននៃកិច្ចសន្យាដែរ រឺទេ?

តាមរយៈការរៀបរាបខាងលើនេះ បង្ហាញឲ្យយើងឃើញថា ការបដិសេធអានុភាពនៃកិច្ចសន្យា គឺអនុវត្តបានតាមរយៈ មោឃភាព និងការលុបចោល។ ការលុបចោលគឺជាវិធីដែលប្រើចំពោះកិច្ចសន្យាមានផលប៉ះពាល់ចំពោះភាគីនៃកិច្ចសន្យា បើប្រៀបទៅនឹងមោឃភាពវិញ គឺបានចំពោះតែកិច្ចសន្យាណាដែលផ្តល់ផលប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់ ផ្ទុយនឹងច្បាប់ បញ្ញត្តិអនុវត្តដោយបង្ខំ ឬ ការបង្ហាញឆន្ទៈមិនពិតជាដើម។ ដោយសារតែប្រធានបទនេះសិក្សាតែ ការលុបចោលកិច្ចសន្យា នាងខ្ញុំនឹងមិនធ្វើការបកស្រាយបន្ថែមពីមោឃភាពនៃកិច្ចសន្យាទៀតទេ ដើម្បីកុំឲ្យមានការឃ្លាតឆ្ងាយពីប្រធានបទ។

ដូចនេះដើម្បីងាយស្រួលក្នុងសិក្សាស្វែងយល់ពី ការលុបចោលកិច្ចសន្យា នាងខ្ញុំបានធ្វើការបែងចែកប្រធានបទនេះជាបីគឺ៖

- *លក្ខខណ្ឌការលុបចោលកិច្ចសន្យា(ជំពូកទី១)*
- *វិធីនៃការលុបចោលកិច្ចសន្យា(ជំពូកទី២)*
- *អានុភាពនៃការលុបចោលកិច្ចសន្យា(ជំពូកទី៣)។*

# ជំពូកទី១
# លក្ខខណ្ឌនៃការលុបចោលកិច្ចសន្យា

## ១.១.និយមន័យ

### ១.១.១.និយមន័យនៃការលុបចោល

ការលុបចោល ឬ Cancellation ជាភាសាអង់គ្លេស គឺជាបច្ចេកទេសមួយដើម្បីធ្វើការបដិសេធអនុភាពនៃកិច្ចសន្យា។[1] ម៉្យាងទៀតការលុបចោលកិច្ចសន្យា ក៏ជាមធ្យោយបាយមួយដែលអាចឲ្យភាគីនៃកិច្ចសន្យាមានសិទ្ធិគ្រប់គ្រាន់ ក្នុងការបង្កើតកិច្ចសន្យាមួយបានយ៉ាងត្រឹមត្រូវស្របទៅតាមឆន្ទៈរបស់គាត់។ ការលុបចោលកិច្ចសន្យា គឺជាសកម្មភាពឯកតោភាគីរបស់បុគ្គលដែលមានសិទ្ធិលុបចោល ដោយសារតែមានមូលហេតុនៃការលុបចោលកិច្ចសន្យាណាមួយ។

### ១.១.២. និយមន័យ «កិច្ចសន្យា»

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់កាតព្វកិច្ច។[2] កិច្ចសន្យាមានអានុភាពដោយការព្រមព្រៀងគ្នា ដែលជាគោលការណ៍សេរីរបស់ភាគីដើម្បីបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យា។

ជាគោលការណ៍ កាលណាមានការព្រមព្រៀងរបស់ភាគីនៃកិច្ចសន្យាដោយសារសំណើ និងស្ទីការត្រូវគ្នា កិច្ចសន្យានឹងបង្កើតអនុភាព[3] លើកលែងតែការបង្កើតកិច្ចសន្យាមួយចំនួនដូចជា ការប្រគល់វត្ថុ ឬ ការរៀបចំលិខិត តម្រូវឲ្យមានលក្ខខណ្ឌដែលចាំបាច់បន្ថែមពីការព្រមព្រៀងគ្នា ទើបកិច្ចសន្យាមានអានុភាព។[4] នេះគឺជាលក្ខខណ្ឌដែលច្បាប់តម្រូវឲ្យបំពេញបន្ថែម ចំពោះកិច្ចសន្យាពិសេសជាក់លាក់ណាមួយ ព្រោះត្រឹមតែមានការព្រមព្រៀង មិនគ្រប់គ្រាន់នោះទេក្នុងការបង្កើតអានុភាពកិច្ចសន្យា។

ម៉្យាងទៀតចំពោះ កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនឹងមានអនុភាព លុះត្រាតែបានធ្វើលិខិតយថាភូត។[5] ការ

[1] មេរៀនភាគ ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៨, ២០១៦។

[2] មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, (ពីពេលនេះតទៅហៅថាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

[3] មាត្រា ៣៣៦ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[4] សេចក្ដីកំណត់ចំពោះមាត្រានីមួយនៃក្រមរដ្ឋប្បវេណីភាគ២, កំណត់មាត្រា៣៣៦។

[5] មាត្រា ៣៣៦ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

កំណត់អំពីលក្ខខណ្ឌបន្ថែមទាំងនេះ គឺដើម្បីធានាបានការការពារអនុប្បទាយី អនុប្បទានិក ជាពិសេសគឺជួយសម្របសម្រួលក្នុងការកាត់បន្ថយវិវាទ ការដោះស្រាយជម្លោះ ឬ ការពារជម្លោះមិនឲ្យកើតមានឡើងនៅពេលដែលមានវិវាទកិច្ចសន្យានៃការអនុប្បទានកម្មសិទ្ធិលើអចលនវត្ថុ។

សំណើរ គឺជាការស្នើសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ[6] ចំណែកស្វីការវិញ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនេះ។[7]

## ១.២.មូលហេតុនៃការលុបចោលកិច្ចសន្យា

### ១.២.១.ករណីជនជនដែលខ្វះសមត្ថភាពខាងឆន្ទៈ

សមត្ថភាពខាងឆន្ទៈមានលក្ខណៈអរូបីយ ព្រោះជាគំនិត ឬ ជាការគិតរបស់បុគ្គលម្នាក់ៗ ដែលស្តែងចេញតាមរយៈសកម្មភាព។ សមត្ថភាពខាងឆន្ទៈ គឺជាសមត្ថភាពដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធភាពតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ ហេតុនេះនៅពេលដែលបុគ្គលម្នាក់បាន ធ្វើសកម្មភាពអ្វីមួយនៅពេលដែលគាត់មិនអាចយល់ដឹង និងវិនិច្ឆ័យបាន សកម្មភាពនោះអាចលុបចោលបាន។[8] សកម្មភាព គឺសំដៅទៅលើកិច្ចសន្យា និងសកម្មភាពឯកតោភាគី។[9]

ជនដែលខ្វះសមត្ថភាពខាងឆន្ទៈអាចមានដូចជា ជនដែលសេពគ្រឿងស្រវឹង ឬ ថ្នាំដែលប៉ះពាល់ដល់ស្មារតី ជនដែលមានជម្ងឺប៉ះពាល់ដល់ស្មារតី ជនចាស់ជរា (វង្វេង ភ្លេចភ្លាំង ឬ មានជម្ងឺរាំរ៉ៃ) ជាដើម។

### ១.២.២.ករណីជនជនដែលខ្វះសមត្ថភាពក្នុងការធ្វើកិច្ចសន្យា

សមត្ថភាពក្នុងការធ្វើ កិច្ចសន្យា គឺជាសមត្ថភាពមួយដែលច្បាប់ទទួលស្គាល់ថាមានអត្ថិភាពពេញលេញក្នុងការធ្វើ កិច្ចសន្យា។ នៅពេលដែល កិច្ចសន្យាអ្វីមួយ ធ្វើឡើងដោយជនដែលត្រូវបានកម្រិតសមត្ថភាព គឺច្បាប់មិនទទួលស្គាល់សុពលភាពនៃ កិច្ចសន្យាឡើយ។

[6] មាត្រា ៣៣៧ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[7] មាត្រា ៣៣៧ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[8] មាត្រា ១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[9] មាត្រា ១៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ជនដែលត្រូវបានកម្រិ តសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថ។[10]

### ១.២.២.១.អនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ឆ្នាំ។[11] អនីតិជនស្ថិតក្រោមរបបអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដូចនេះនៅពេលដែលអនីតិជនធ្វើ កិច្ចសន្យាដោយមិនមានការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន កិច្ចសន្យារបស់អនីតិជន នឹងអាចលុបចោលបាន។[12]អ្នកមានសិទ្ធិអំណាចមេបា ជាឪពុកម្តាយ ឬ ឪពុកម្តាយចិញ្ចឹម។[13] អ្នកអាណាព្យាបាលសម្រាប់អនីតិជនវិញត្រូវចាប់ផ្តើមដោយតុលាការ នៅពេលដែលមិនមានអ្នកអនុវត្តសិទ្ធិអំណាចមេបាសម្រាប់អនីតិជន។[14]

ជាគោលការណ៍ កិច្ចសន្យាដែលធ្វើឡើងដោយអនីតិជន អាចលុបចោលបាន ក្នុងគោលបំណងដើម្បីការពារអនីតិជន ក៏ព្រោះតែកម្រិតនៃការយល់ដឹង ការវិនិច្ឆ័យ រួមទាំងការពិចារណារបស់អនីតិជននៅមានកម្រិតដែលនាំឲ្យអនីតិជនប្រឈមនឹងការខូចខាតផលប្រយោជន៍នៅពេលដែលពួកគេធ្វើសកម្មភាពអ្វីមួយ។

ប៉ុន្តែ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាក៏បានបញ្ញត្តិនូវករណីលើកលែងនូវ កិច្ចសន្យាមួយចំនួនដែលអនីតិជនអាចធ្វើសកម្មភាពបានដោយគ្មានការយល់ព្រមពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានដែរ។ កិច្ចសន្យាទាំងមានដូចជាកិច្ចសន្យាដែលនាំឲ្យអនីតិជនទទួលសិទ្ធិ ឬ រួចផុតពីកាតព្វកិច្ច ឬ កិច្ចសន្យាដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។[15]

កិច្ចសន្យាដែលនាំឲ្យអនីតិជនទទួលសិទ្ធិ គឺសំដៅដល់កិច្ចសន្យាណាដែលអនីតិជនទទួលបានជាសិទ្ធិទាំងស្រុងដោយគ្មានកាតព្វកិច្ចតបឡើយ ដូចជាប្រទានកម្ម ឬ អំណោយពីញាតិឬបុគ្គលណាម្នាក់។ ចំណែកឯការឲ្យរួចផុតពីការកាតព្វកិច្ច សំដៅទៅលើការលើកលែងកាតព្វកិច្ចឲ្យអនីតិជន ដូចជាការមិនបាច់ឲ្យអនីតិជនសងប្រាក់ជាដើម។

---

[10] មាត្រា ១៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[11] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[12] មាត្រា ១៨ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[13] មាត្រា ១០៣៥-១០៣៦, ១០៣៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[14] មាត្រា ១០៦៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[15] មាត្រា ១៨ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ម៉្យាងទៀតចំពោះ កិច្ចសន្យាដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃវិញ គឺទាក់ទងទៅការទិញសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ( ដូចជាសៀវភៅ នំ អាហារ ភេសជ្ជៈ...)។ល។ កិច្ចសន្យាដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ មានដូចជាកិច្ចសន្យាដែលមានភាពងាយស្រួលក្នុងការវិនិច្ឆ័យ ជាទូទៅមានទឹកប្រាក់ទាប ដែលមិនមានការព្រួយបារម្ភពីការខូចខាតផលប្រយោជន៍របស់អនីតិជន ពោលគឺអនីតិជនអាចធ្វើសកម្មភាពទាំងនេះដោយមានសុពលភាពតែម្នាក់ឯងបាន។ ប៉ុន្តែអ្វីដែលគួរឲ្យពិចារណា គឺ កិច្ចសន្យាណាដែលអាចចាត់ទុកថាជា សកម្មភាពប្រចាំថ្ងៃ ព្រោះជីវភាពរស់នៅប្រចាំថ្ងៃរបស់អនីតិជនម្នាក់ៗមិនមានកម្រិតដូចគ្នាទេ។

អនីតិជនអាចធ្វើការចាត់ចែងទ្រព្យសម្បត្តិដែល អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឲ្យចាត់ចែង ក្នុងទំហំនៃគោលបំណងដែលបានកំណត់ ព្រមទាំងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាកសម្រាប់អនីតិជនបានអនុញ្ញាតឲ្យចាត់ចែងដោយមិនបានកំណត់គោលដៅផងដែរ។[16]

ដូចគ្នាផងដែរ ចំពោះការប្រកបអាជីវកម្មរបស់អនីតិជន ក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា «អនីតិជនដែលបានទទួលការអនុញ្ញាតឲ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជន ចំពោះមុខជំនួញនោះ»។[17] មានន័យថា អនីតិជនដែលទទួលបានការអនុញ្ញាតពីអ្នកមានអំណាចមេបាឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានសមត្ថភាពពេញលេញក្នុងការធ្វើសកម្មភាពដែលចាំបាច់សម្រាប់អាជីវកម្មបាន ដូចជា ជួលសេវាកម្មតុបតែលម្អ ជួលបុគ្គល ទិញទំនិញចេញចូល ទិញសម្ភារៈចាំបាច់សម្រាប់អាជីវកម្មជាដើម ដោយពុំចាំបាច់ទទួលការអនុញ្ញាតពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនម្តងទៀតទេ ។ ពោលគឺអាចឲ្យអនីតិជននោះធ្វើសកម្មភាពទាំងនេះបានដោយឯករាជ្យ ហើយមិនអាចលុបចោលដោយមូលហេតុអនីតិជនបានឡើយ។

ជាមួយគ្នានេះដែរ ប្រសិនជាអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឲ្យអនីតិជនប្រកបអាជីវកម្មរួចហើយ ប៉ុន្តែក្រោយមកគាត់បែរជាដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនេះបាន ដោយអនីតិជននោះអសមត្ថភាពក្នុងការធ្វើអាជីវកម្ម ដូចជាលក់ទំនិញដែលគ្មានទីផ្សារ យកលុយចំណេញទៅចាយវាយផ្តេសផ្តាស ឬ ទីតាំងអាជីវកម្មមិនសមប្រកប ចំណូលអាជីវកម្មមិនអាច

[16] មាត្រា ១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[17] មាត្រា ២០ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ទប់ទល់នឹងចំណាយជាដើម អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនេះបាន។[18]

នៅពេលដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានលុបចោលការអនុញ្ញាតនៃការប្រកបអាជីវកម្ម សមត្ថភាពក្នុងការធ្វើកិច្ចសន្យារបស់អនីតិជននឹងត្រឡប់ទៅស្ថានភាពដើមវិញ ដូចកាលមិនទាន់ទទួលបានការអនុញ្ញាតឲ្យប្រកបអាជីវកម្ម ។

មួយវិញទៀត ប្រសិនបើអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនលុបចោលការអនុញ្ញាតទេ គ្រាន់តែកម្រិតនៅការធ្វើអាជីវកម្ម។ ចំពោះកិច្ចសន្យាការងាររបស់អនីតិជនវិញ អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់ អនីតិជន មិនអាចចុះកិច្ចាសន្យាការងារជំនួសអនីតិជនបានឡើយ ហើយទោះបីជាបានធ្វើកិច្ចសន្យាហើយក៏ដោយ ក៏កិច្ចសន្យាមិនមានអានុភាពចំពោះសាមីអនីតិជនដែរ លើកតែអនីតិជនបានផ្ដល់សច្ចានុមតិលើកិច្ចសន្យា។[19] នៅក្នុងករណី ដែលយល់ឃើញថាកិច្ចសន្យាការងាររបស់អនីតិជន ធ្វើឲ្យខូចខាតផលប្រយោជន៍របស់អនីតិជន អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ស្ថាប័នរដ្ឋ អាចរំលាយកិច្ចសន្យាឆ្ពោះទៅអនាគតបាន។[20]

ដោយឡែក អនីតិជនដែលទទួលបានអត្តាធីនភាព ត្រូវបានចាត់ទុកថាដល់នីតិភាព។[21] មានន័យថាអនីតិជនដែលទទួលបានអត្តាធីនភាព អាចបង្កើតកិច្ចសន្យាបានដោយមានសុពលភាព ហើយមិនអាចធ្វើការលុបចោលកិច្ចសន្យា ដោយហេតុថាមិនមានការយល់ព្រមពីអ្នកអាណាព្យាបាលបានឡើយ។[22]

### ១.២.២.២.ជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធភាពតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារវិបត្តិផ្នែកស្មារតី ហើយត្រូវបានតុលាការប្រកាសរបបអាណាព្យាបាលទូទៅតាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតក្នុង ៤

---

[18] មាត្រា ២០ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[19] មាត្រា ២៣ កថាខណ្ឌ១,២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[20] មាត្រា ២៣ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[21] មាត្រា ២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[22] មេរៀនភាគ ១ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ១៥, ២០១៥។

ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ។[23]

ជនដែលបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ត្រូវហៅថា ជននៅក្រោមអាណាព្យាបាលទូទៅហើយតុលាការត្រូវប្រកាសជ្រើសតាំងអ្នកអាណាព្យាបាលទូទៅដើម្បី ថែរក្សាជននៅក្រោមអាណាព្យាបាលទូទៅ[24] ជាពិសេសជាអ្នកតំណាង និងជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ។ មានន័យថា អ្នកអាណាព្យាបាលទូទៅ ជាអ្នកធ្វើកិច្ចសន្យាទាក់ទងនឹងទ្រព្យសម្បត្តិក្នុងនាមជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ។[25]

ប្រសិនបើ ជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅធ្វើកិច្ចសន្យាដោយខ្លួនឯង អ្នកអាណាព្យាបាលអាចទូទៅអាចលុបចោលបាន លើកលែងតែកិច្ចសន្យាដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ[26] កិច្ចសន្យាដែលទាក់ទងនឹងជីវភាពរស់ប្រចាំថ្ងៃ គឺជាកិច្ចសន្យាដែលទាក់ទងនឹងការរស់នៅរាល់ថ្ងៃ ដូចជាការទិញរបស់ប្រើប្រាស់ប្រចាំថ្ងៃ ការទិញនំចំណីជាដើម។[27] ដោយសារតែការធ្វើសកម្មភាពទាក់ទងនឹងជីវភាពប្រចាំថ្ងៃ មិនបណ្តាលឲ្យមានការបាត់បង់ផលប្រយោជន៍ធ្ងន់ធ្ងរចំពោះជននៅក្រោមអាណាព្យាបាលទូទៅទេ ហើយដើម្បីបង្កភាពងាយស្រួលដល់ការរស់នៅរបស់ជននៅក្រោមអាណាព្យាបាលទូទៅក្នុងការទិញរបស់ប្រើប្រាស់ប្រចាំថ្ងៃដោយខ្លួនឯងបាន។

ពេលជននៅក្រោមអាណាព្យាបាលទូទៅ មានភាពប្រក្រតីផ្នែកបញ្ញាស្មារតីឡើងវិញ តុលាការត្រូវប្រកាសលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់ សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុងបួនថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានជននោះ ឬ តំណាងអយ្យការ។[28]

ក្រោយពេលដែលលុបចោលរបបអាណាព្យាបាលទូទៅ ជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅនឹងក្លាយជាសមត្ថជនវិញ ហើយអាចធ្វើកិច្ចសន្យាដោយមានសុពលភាពជាធម្មតា។

---

[23] មាត្រា ២៤ កថាខណ្ឌ១ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[24] មាត្រា ២៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[25] មាត្រា ១១១៤ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[26] មាត្រា ២៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[27] សេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមរដ្ឋប្បវេណីភាគ១, កំណត់មាត្រា២៦។

[28] មាត្រា ២៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

### ១.២.២.៣.ជននៅក្រោមហិតូបត្ថម្ភ

ជននៅក្រោមហិតូបត្ថម្ភ គឺជាជនដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធភាពតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកស្មារតី តុលាការអាចប្រកាសចាប់ផ្តើមហិតូបត្ថម្ភលើជននោះបានតាមពាក្យសុំរបស់ សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុងបួនថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអាណាព្យាបាល មេឃុំ ឬចៅសង្កាត់នៃលំនៅឋានជននោះ ឬ តំណាងអយ្យការ។[29]សមត្ថភាពតិចតួចពេក គឺសំដៅទៅលើសមត្ថភាពខាងឆន្ទៈដែលកម្រិតនៃការវិនិច្ឆ័យទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិគឺទាបខ្លាំងជាងធម្មតា។ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអាណាព្យាបាល ត្រូវបានបញ្ចូលជាអ្នកដែលមានសិទ្ធិដាក់ពាក្យសុំឲ្យប្រកាសចាប់ផ្តើមហិតូបត្ថម្ភ គឺដោយសារពេលខ្លះករណីពិការភាពខាងផ្លូវចិត្តរបស់ជននៅក្រោមអាណាព្យាបាលទូទៅបានធូរស្រាល ហើយត្រូវប្តូរឲ្យស្ថិតក្រោមរបបហិតូបត្ថម្ភវិញ និងដើម្បីងាយស្រួលការពារ និងគ្រប់គ្រងក្រោមរបបហិតូបត្ថម្ភវិញ។

ជនដែលត្រូវទទួលបានការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ត្រូវហៅថា ជននៅក្រោមហិតូបត្ថម្ភ ហើយតុលាការត្រូវជ្រើសរើសហិតូបត្ថម្ភកៈ ដើម្បីថែរក្សាជននៅក្រោមហិតូបត្ថម្ភ។[30]

ហិតូបត្ថម្ភកៈ អាចផ្តល់ការយល់ព្រមទៅជននៅក្រោមហិតូបត្ថម្ភ ចំពោះកិច្ចសន្យាដែលបានធ្វើដោយជនស្ថិតនៅក្រោមហិតូបត្ថម ប៉ុន្តែហិតូបត្ថម្ភកៈមិនមែនជាអ្នកតំណាង ដូចអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលទូទៅទេ។ មានន័យថាហិតូបត្ថម្ភកៈមិនអាចចុះកិច្ចសន្យា ក្នុងនាមជាអ្នកតំណាងឲ្យជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភបានទេ។ កិច្ចសន្យាដែលត្រូវទទួលការយល់ព្រមពីហិតូបត្ថម្ភកៈមានដូចខាងក្រោម៖[31]

- ការទទួល ឬ ការប្រើប្រាស់ទុន
- ការខ្ចីទ្រព្យ ឬ ការធានា
- ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬ ធ្វើឲ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬ ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត
- ការធ្វើសកម្មភាពបណ្តឹង
- ការធ្វើប្រទានកម្ម ឬ កិច្ចសន្យាស្រុះស្រួល ឬ កិច្ចសន្យាមជ្ឈតកម្ម
- ការទទួលស្គាល់នូវសន្តតិកម្ម ឬ ការបោះបង់នូវសិទ្ធិសន្តតិកម្ម ឬ ការបែងចែកនូវមត៌ក

[29] មាត្រា ២៨ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[30] មាត្រា ២៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[31] មាត្រា ៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

- ការប្រកែកមិនទទួលប្រទានកម្ម ឬ អច្ច័យទាន ឬ ការយល់ព្រមទទួលនូវប្រទានកម្ម ឬ អច្ច័យទាន ដែលភ្ជាប់នឹងបន្ទុក
- ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬ ការជួសជុលធំ
- ការធ្វើកតិសន្យា ដែលមានអំឡុងពេលលើសពីបីឆ្នាំចំពោះដីធ្លី លើសពីពីរឆ្នាំចំពោះអគារ លើសពីប្រាំមួយខែចំពោះចលនវត្ថុ
- សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវតែមានការយល់ព្រមពីហិតូបត្ថម្ភកៈ តាមពាក្យសុំរបស់ជនដែលមានសិទ្ធិដាក់ពាក្យសុំទៅតុលាការឲ្យប្រកាសហិតូបត្ថម្ភ។

ក្នុងករណីដែលជនស្ថិតនៅក្រោមហិតូបត្ថមធ្វើកិច្ចសន្យាខាងលើ ដោយគ្មានការយល់ព្រមពីហិតូបត្ថមកៈ ហិតូបត្ថមកៈអាចលុបចោលកិច្ចសន្យាទាំងនោះបាន។

នៅពេលដែលជននៅក្រោមហិតូបត្ថម្ភ មានភាពប្រក្រតីផ្នែកស្មារតីឡើងវិញ នោះមិនមានភាពចាំបាច់ដើម្បីកម្រិតសមត្ថភាពជននោះទៀតទេ ដូច្នោះតុលាការត្រូវប្រកាសលុបចោលនូវការចាប់ផ្តើមហិតូបត្ថម្ភ តាមពាក្យសុំរបស់ សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុងបួនថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានជននោះ ឬ តំណាងអយ្យការ។[32]

### ១.២.៣.ករណីវិការៈនៃការបង្ហាញឆន្ទៈ

ដើម្បីជាមូលដ្ឋាន ក្នុងការយល់ឲ្យបានច្បាស់លាស់នៃការបង្ហាញឆន្ទៈដោយមានវិការៈ យើងគប្បីស្វែងនូវអត្ថន័យនៃពាក្យ «វិការៈ» និង «ការបង្ហាញឆន្ទៈ» ជាមុនសិន។

ពាក្យ «វិការៈ» មានន័យថា ការប្រែប្រួលចាកពីភាពប្រក្រតី។[33] ចំណែងពាក្យ «ការបង្ហាញឆន្ទៈ» វិញ គឺជាការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុគតិយុត្ត។[34] ដូច្នោះ វិការៈនៃការបង្ហាញឆន្ទៈ មានន័យថា ជាការប្រែប្រួលចាកពីភាពប្រក្រតី នៃការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្ត។

កិច្ចសន្យាមានអានុភាពនៅពេលដែលមានការបង្ហាញឆន្ទៈរបស់ភាគីទាំងវិញទៅមក ហេតុនេះហើយ ប្រសិនជាការបង្ហាញឆន្ទៈរបស់ភាគីមិនមានសុពលភាពដែលជាធាតុផ្សំនៃកិច្ចសន្យា នាំឲ្យកិច្ចសន្យាមិនមាន

---

[32] មាត្រា ៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[33] សន្ទានុក្រម ផ្នែកក្រមរដ្ឋប្បវេណី ចំណុច១៣៥។

[34] មាត្រា ៣១០ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ចំណង ឬ អានុភាពចំពោះភាគីនោះទេ។ ករណីដែលការបង្ហាញឆន្ទៈរបស់ភាគីមានវិការៈ ពីព្រោះតែការបង្ហាញឆន្ទៈបែបនេះមិនត្រូវបានទទួលស្គាល់ ដែលក្រមរដ្ឋប្បវេណីបានដោះស្រាយចំពោះបញ្ហានេះ ដោយអនុញ្ញាតឲ្យភាគីអាចលុបចោលកិច្ចសន្យាដែលបានកំណត់អំពីស្ថានភាពដែលចាត់ទុកថាមានវិការៈនេះបាន ។

ស្ថានភាពដែលចាត់ទុកថាជាវិការៈនៃការបង្ហាញឆន្ទៈរួមមាន ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ការគម្រាមកំហែង ការបង្ហាញព័តមានមិនពិត និងការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយមានគោលបំណងកេងយកចំណេញហួសហេតុ។[35]

### **១.២.៣.១.ការភាន់ច្រឡំ**

ការភាន់ច្រឡំ គឺជាការបង្ហាញឆន្ទៈដោយយល់ខុសដោយខ្លួនឯងអំពីចំណុចណាមួយនៃកិច្ចសន្យា។[36] ការភាន់ច្រឡំគឺជាស្ថានភាពដែលអ្នកបង្ហាញឆន្ទៈ បានធ្វើការបង្ហាញឆន្ទៈខុសគ្នាទៅនឹងការបង្ហាញឆន្ទៈរបស់ខ្លួន ហើយអ្នកបង្ហាញឆន្ទៈក៏មិនបានដឹងផងដែរ។

ដើម្បីអាចលុបចោលកិច្ចសន្យាដែលមានការភាន់ច្រឡំបាន លុះត្រាតែបានបំពេញលក្ខខណ្ឌនីមួយៗនៃការភាន់ច្រឡំដែលរួមមាន ការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា ការភាន់ច្រឡំចំណុចសំខាន់របស់ភាគី និងការភាន់ច្រឡំរួមគ្នា។

#### **ក.ការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា**

ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់នៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលមានការភាន់ច្រឡំអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[37] ដូចនេះលក្ខខណ្ឌនៃការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា មាន ២ គឺ៖[38]

(១) អ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំលើចំណុចសំខាន់ក្នុងកិច្ចសន្យា គឺអ្នកបង្ហាញឆន្ទៈបានយល់ខ្លួនឯងដោយអន្តោម័តទៅលើចំណុចដែលសំខាន់ក្នុងកិច្ចសន្យាដែលខុសពីការពិត ហើយចំណុចសំខាន់នេះគឺជា

---

[35] មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[36] មេរៀនភាគ ១ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ២២, ២០១៥។

[37] មាត្រា ៣៤៦ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[38] មេរៀនភាគ ១ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ២៣, ២០១៥។

ចំណុចដែលសាធារណៈជនយល់ឃើញថាសំខាន់នៅក្នុងការបង្កើតកិច្ចសន្យា ព្រោះកាលណាមានការភាន់ច្រឡំ គឺផ្ទុយពីឆន្ទៈរបស់អ្នកបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យា។

(២) ភាគីម្ខាងទៀតអាចដឹងអំពីការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ គឺដើម្បីការពារភាគីម្ខាងទៀតកុំឲ្យទទួលរងនូវការខូចខាតដែលមិនបានគិតទុកជាមុន នៅពេលដែលអ្នកបង្ហាញឆន្ទៈភាន់ច្រឡំ បង្ហាញឆន្ទៈចង់លុបចោលកិច្ចសន្យា។ លទ្ធភាពក្នុងការដឹងអំពី ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ មិនមែនជាលក្ខខណ្ឌសកម្មដែលត្រូវបានបញ្ជាក់ពីភាគីដែលបង្ហាញឆន្ទៈភាន់ច្រឡំនោះទេ តែជាបន្ទុកក្នុងការបញ្ជាក់របស់ភាគីម្ខាងទៀត ក្នុងអះអាងថាខ្លួនបានដឹង ឬ អាចដឹងអំពីការភាន់ច្រឡំនេះ។

អ្វីដែលចាំបាច់ក្នុងការបកស្រាយទៅលើលក្ខខណ្ឌនេះ គឺចំណុចសំខាន់នៃកិច្ចសន្យា។ តើអ្វីដែលអាចចាត់ទុកថាជា ចំណុចសំខាន់នៃកិច្ចសន្យា? ចំណុចសំខាន់នៅក្នុងកិច្ចសន្យា គឺជាដែលមនុស្ស រួមទាំងភាគីទូទៅទទួលស្គាល់ថាសំខាន់នៅក្នុងកិច្ចសន្យា។ ក្នុងកិច្ចសន្យានីមួយៗគឺ តែងតែមានចំណុចសំខាន់នៃកិច្ចសន្យា ហើយចំណុចសំខាន់នៃកិច្ចសន្យានេះ គឺអាស្រ័យទៅលើប្រភេទនៃកិច្ចសន្យានីមួយៗដែលអាចជា តម្លៃ កម្មវត្ថុ ជាដើម។ ចំពោះកិច្ចសន្យាលក់ទិញ ថ្លៃលក់គឺជាចំណុចសំខាន់សម្រាប់អ្នកទិញ និងអ្នកលក់ទាំងអស់។ ចំណែកឯ កិច្ចសន្យាការងារវិញ បុគ្គលដែលត្រូវមកធ្វើការទើបជាចំណុចសំខាន់។

### ខ.ការភាន់ច្រឡំចំណុចសំខាន់របស់ភាគី

ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចសំខាន់នៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលភាន់ច្រឡំអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ។[39]

ផ្អែកលើចំណុចខាងលើនេះ ដើម្បីលុបចោលកិច្ចសន្យាដោយផ្អែកលើការភាន់ច្រឡំ អំពីចំណុចសំខាន់នៃកិច្ចសន្យាដែលអ្នកបង្ហាញឆន្ទៈយល់ឃើញ ត្រូវ ត្រូវបំពេញលក្ខខណ្ឌដូចជា៖

(១) អ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា គឺអ្នកបង្ហាញឆន្ទៈមានការយល់ឃើញដោយអត្តនោម័តដោយខ្លួនឯងថាជាចំណុចសំខាន់នៃកិច្ចសន្យា ហើយអាចមិនពាក់ព័ន្ធទៅនឹងកម្មវត្ថុចម្បងនៃកិច្ចសន្យា ព្រោះនេះគឺជាចំណុចសំខាន់សម្រាប់អ្នកបង្ហាញឆន្ទៈប៉ុណ្ណោះ បើមិនមានចំណុចសំខាន់ ក៏ អ្នកបង្ហាញឆន្ទៈមិន

[39] មាត្រា ៣៤៦ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

បង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យាដែរ តែសម្រាប់សាធារណៈទូទៅវិញអាចគិតថាមិនមែនជាចំណុចសំខាន់ ចំណែកចំណុចដែលអ្នកបង្ហាញឆន្ទៈយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា គឺជាករណីដែលត្រូវបាន ហៅថាជា ការភាន់ច្រឡំអំពីមូលហេតុ មានន័យថា អ្នកបង្ហាញឆន្ទៈមានការយល់ឃើញថានៅពេលដែលបង្កើត កិច្ចសន្យាហើយ គាត់អាចប្រើប្រាស់កម្មវត្ថុក្នុងកិច្ចសន្យាទៅតាមគោលបំណងរបស់គាត់ ប៉ុន្តែផ្ទុយមកវិញកម្មវត្ថុ នៃកិច្ចសន្យានេះ មិនអាចប្រើប្រាស់ទៅតាមវត្ថុបំណងរបស់គាត់បានទេ ហើយគោលបំណងនៃការបង្កើត កិច្ចសន្យានេះ គឺហេតុផលអត្តនោម័តរបស់អ្នកបង្ហាញឆន្ទៈមានលក្ខខណៈអរូបី។

(២) អំពីការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ គឺអ្នកបង្ហាញឆន្ទៈពិតជាមានការភាន់ច្រឡំពិតប្រាកដក្នុងការ បង្កើតកិច្ចសន្យា ហេតុនេះអ្នកបង្ហាញឆន្ទៈភាន់ច្រឡំ អាចលុបចោលកិច្ចសន្យាបាន។ ប៉ុន្តែដោយសារតែការ លុបចោលរបស់អ្នកបង្ហាញឆន្ទៈដោយភាន់ច្រឡំ គឺកើតឡើងដោយសារតែការភាន់ច្រឡំរបស់ខ្លួនគាត់ ហើយធ្វើ ឲ្យខូចខាតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀត ហេតុដូច្នេះទើបតម្រូវឲ្យមានលក្ខខណ្ឌ ភាគីម្ខាងទៀតបាន ដឹងអំពីចំណុចសំខាន់ដែលអ្នកបង្ហាញឆន្ទៈបានយល់ឃើញ។

(៣) ភាគីម្ខាងទៀតបានដឹងអំពីចំណុចសំខាន់ដែលអ្នកបង្ហាញឆន្ទៈយល់ឃើញ ជាទូទៅភាគីម្ខាងទៀត មិនអាចដឹងបានទេថា អ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈភាន់ច្រឡំអំពីចំណុចសំខាន់ដែលអ្នកបង្ហាញឆន្ទៈបាន យល់ឃើញ ប្រសិនជាអ្នកបង្ហាញឆន្ទៈមិនបានបង្ហាញអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យាទៅដល់ភាគីម្ខាងទៀត ប៉ុន្តែក៏មានករណី ដែលភាគីម្ខាងទៀតបានដឹងថា អ្វីជាចំណុចសំខាន់ដែលអ្នកបង្ហាញឆន្ទៈបានយល់ឃើញ តាមរយៈទម្លាប់ ជំនឿ សាសនា ក្បួនហ៊ុងស៊ុយ អាជីវកម្ម ឬ សកម្មភាពប្រចាំថ្ងៃរបស់អ្នកបង្ហាញឆន្ទៈ ដោយសារធ្វើជំនួញជាប្រចាំ ជាមួយគ្នា ជាមិត្តស្និទស្នាល ជាញាតិជាដើម។ ក្នុងករណីនេះ ភាគីដែលបង្ហាញ ឆន្ទៈភាន់ច្រឡំ ត្រូវរក សំអាងបញ្ជាក់ថា ភាគីម្ខាងទៀតបានដឹងអំពីការបង្ហាញឆន្ទៈនេះ។

### គ.ការភាន់ច្រឡំរួមគ្នា

ក្នុងករណីដែលភាគីទាំងសងខាង មានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃ កិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងយល់ឃើញថាសំខាន់ ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងទៀតមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀត

ក៏ដោយ ក៏ភាគីម្ខាងដែលបានភាន់ច្រឡំអាចលុបចោលកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[40]

យោងតាមមាត្រា ៣៤៦ កថាខណ្ឌទី៣ខាងលើ លក្ខខណ្ឌដែលត្រូវបំពេញនៃការភាន់ច្រឡំរួមគ្នាមាន៖[41]

(១) ភាគីទាំងសងខាងមានការភាន់ច្រឡំ គឺអ្នកបង្ហាញឆន្ទៈ និងភាគីម្ខាងទៀតមានការភាន់ច្រឡំដូចគ្នាទៅលើខ្លឹមសារនៃកិច្ចសន្យា ដូចជាតាវកាលិក ថ្លៃលក់ទិញ ឬ សិទ្ធិជាដើម។

(២) ចំណុចដែលមានការភាន់ច្រឡំលើចំណុចសំខាន់នៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ថាសំខាន់ក្នុងការបង្កើតកិច្ចសន្យាគឺជាផ្នែកសំខាន់ជាសត្យានុម័តនៃកិច្ចសន្យា ជាផ្នែកនៃកិច្ចសន្យាដែលភាគីយល់ឃើញថាសំខាន់ និងជមូលហេតុនៃការបង្កើតកិច្ចសន្យា។

ភាគីនៃកិច្ចសន្យាអាចលុបចោលកិច្ចសន្យា ដោយផ្អែកលើការភាន់ច្រឡំរួមបានទោះបីជាភាគីម្ខាងគ្មានលទ្ធភាពដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ។[42] មានន័យថា ភាគីអាចលុបចោលកិច្ចសន្យាដោយមិនចាំបាច់បញ្ជាក់ថាភាគីម្ខាងទៀតបានដឹង ឬ អាចដឹងអំពីការភាន់ច្រឡំរបស់ខ្លួន ដែលខុសពីការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា និងការភាន់ច្រឡំចំណុចសំខាន់របស់អ្នកបង្ហាញឆន្ទៈឡើយ ដើម្បីបង្កភាពងាយស្រួលក្នុងការសង្គ្រោះប្រយោជន៍របស់ភាគី។

### ១.២.៣.២.ការឆបោក

ការបង្ហាញឆន្ទៈដោយការឆបោក គឺជាការបង្ហាញឆន្ទៈយល់ខុសពីការពិតនៃកិច្ចសន្យាតាមរយៈការកុហកបោកប្រាស់ ការប្រើប្រាស់ល្បិចកល ឬ តាមមធ្យោបាយផ្សេងៗដោយបុគ្គលណាម្នាក់។ ការឆបោក អាចប្រព្រឹត្តដោយភាគីនៃកិច្ចសន្យា ឬ តតិយជន។

អ្នកបង្ហាញឆន្ទៈដោយការឆបោករងនូវភាពអយុត្តិធម៌ និងគួរឲ្យការពារជាងអ្នកបង្ហាញឆន្ទៈដោយការភាន់ច្រឡំ។ ដូចនេះហើយ ទោះបីជាអ្នកបង្ហាញឆន្ទៈរងនូវការឆបោកលើចំណុចសំខាន់នៃកិច្ចសន្យាក្តី ចំណុចដែលខ្លួនយល់ឃើញក្តី ឬ ចំណុចដែលមិនសំខាន់ក្តី ក៏អ្នកបង្ហាញឆន្ទៈដោយការឆបោកអាចលុបចោលកិច្ចសន្យាបានផងដែរ ប្រសិនជាបំពេញលក្ខខណ្ឌដែលបានកំណត់ដោយក្រមរដ្ឋប្បវេណី។

[40] មាត្រា ៣៤៦ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[41] មេរៀនភាគ ១ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ២៤, ២០១៥។

[42] សេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមរដ្ឋប្បវេណីភាគ២, កំណត់មាត្រា៣៤៦។

### ក.ការឆបោកដោយភាគីនៃកិច្ចសន្យា

ដើម្បីលុបចោលកិច្ចសន្យាដោយផ្អែកលើការឆបោកដោយភាគី ត្រូវបំពេញលក្ខខណ្ឌដូចជា ៖[43]

(១) សកម្មភាពបោកបញ្ឆោត ឬ បំភ្លៃការពិតរបស់ភាគីនៃកិច្ចសន្យា គឺអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈយល់ព្រមបង្កើតកិច្ចសន្យាដោយសារតែការទទួលព័ត៌មានក្លែងក្លាយ មធ្យោយបាយក្លែងបន្លំ ឬ សកម្មភាពបោកប្រាស់ពីភាគីនៃកិច្ចសិន្យា។

(២) ចេតនានៃការឆបោករបស់ភាគីនៃកិច្ចសន្យា ចេតនានៃការឆបោករបស់ភាគីនៃកិច្ចសន្យា គឺភាគីនៃកិច្ចសន្យាមានចេតនា ក្នុងការកុហក បោកប្រាស់ ឬ ប្រើប្រាស់កលល្បិចផ្សេងៗ រៀបចំឲ្យដូចជាការពិត ដើម្បីឲ្យអ្នកបង្ហាញឆន្ទៈជឿទុកចិត្តថាជាការពិត។ ការយល់ច្រឡំអង្គហេតុរបស់អ្នកបង្ហាញឆន្ទៈ គឺអ្នកបង្ហាញឆន្ទៈបានយល់ខុសពីការពិតជាក់ស្តែង ហើយបានបង្ហាញឆន្ទៈដោយការភាន់ច្រឡំលើអង្គហេតុ ដោយមិនដឹងថាការយល់ខ្លួនខុសពីការពិត ផ្ទុយពីអ្វីដែលមានឡើយ។

(៣) ការយល់ច្រឡំអង្គហេតុរបស់អ្នកបង្ហាញឆន្ទៈ គឺអ្នកបង្ហាញឆន្ទៈបានយល់ខុសពីការពិតជាក់ស្តែង ហើយបានបង្ហាញឆន្ទៈដោយការភាន់ច្រឡំលើអង្គហេតុ ដោយមិនដឹងថាការយល់ខ្លួនខុសពីការពិត ផ្ទុយពីអ្វីដែលមានឡើយ។

(៤) ការបង្ហាញឆន្ទៈដោយការភាន់ច្រឡំលើអង្គហេតុគឺខុសពីឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈ ទោះបីជាអ្នកបង្ហាញឆន្ទៈដោយការឆបោក គឺមានកំហុសដោយសារធ្វេសប្រហែលឲ្យគេបោកបានក៏ដោយ ក៏ចាំបាច់ត្រូវតែការពារអ្នកបង្ហាញឆន្ទៈដែរ ព្រោះភាគីម្ខាងទៀតនៃកិច្ចសន្យា គឺមានគំនិតទុច្ចរិត ក្នុងការឆបោកអ្នកបង្ហាញឆន្ទៈឲ្យបង្កើតកិច្ចសន្យា។

### ខ.ការឆបោកដោយតតិយជន

ផ្អែកលើមាត្រា ៣៤៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ដើម្បីលុបចោលកិច្ចសន្យាផ្អែកលើការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈត្រូវបង្ហាញនូវលក្ខខណ្ឌដូចខាងក្រោម៖

(១) សកម្មភាពបោកបញ្ឆោត ឬ បំភ្លៃការពិតរបស់តតិយជន គឺអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈយល់ព្រមបង្កើតកិច្ចសន្យាដោយសារតែការទទួលព័ត៌មានក្លែងក្លាយ មធ្យោយបាយក្លែងបន្លំ ឬ សកម្មភាពបោកប្រាស់ពីតតិយជន។

[43] មាត្រា ៣៤៧ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

(២) ចេតនានៃការឆបោករបស់តតិយជន គឺតតិយជន មានចេតនា ក្នុងការកុហក បោកប្រាស់ ឬ ប្រើប្រាស់កលល្បិចផ្សេងៗ រៀបចំឲ្យដូចជាការពិត ដើម្បីឲ្យអ្នកបង្ហាញឆន្ទៈជឿទុកចិត្តថាជាការពិត។

(៣) ការយល់ច្រឡំអង្គហេតុរបស់អ្នកបង្ហាញឆន្ទៈ គឺអ្នកបង្ហាញឆន្ទៈបានយល់ខុសពីការពិតជាក់ស្តែង ហើយបានបង្ហាញឆន្ទៈដោយការភាន់ច្រឡំលើអង្គហេតុ ដោយមិនដឹងថាការយល់ខ្លួនខុសពីការពិត ផ្ទុយពីអ្វីដែលមានឡើយ។

(៤) ការបង្ហាញឆន្ទៈដោយការភាន់ច្រឡំលើអង្គហេតុ គឺអ្នកបង្ហាញឆន្ទៈបានយល់ខុសពីការពិតជាក់ស្តែង ហើយបានបង្ហាញឆន្ទៈដោយការភាន់ច្រឡំលើអង្គហេតុ ដោយមិនដឹងថាការយល់ខ្លួនខុសពីការពិត ផ្ទុយពីអ្វីដែលមានឡើយ។

(៥) ភាគីម្ខាងទៀតបានដឹង ឬ អាចដឹងអំពីការឆបោករបស់តតិយជន គឺជាលក្ខខណ្ឌពិសេសមួយដើម្បីការពារភាគីម្ខាងទៀតនៃកិច្ចសន្យា ព្រោះប្រសិនជាអ្នកបង្ហាញឆន្ទៈលុបចោលកិច្ចសន្យាដោយការឆបោករបស់តតិយជន នោះនឹងបណ្តាលឲ្យភាគីម្ខាងទៀតនៃកិច្ចសន្យាទទួលរងការខូចខាតដោយមិនបានគិតទុកជាមុន បើគាត់សុចរិត ហើយមិនបានដឹងពីការឆបោករបស់តតិយជនទៅលើអ្នកបង្ហាញឆន្ទៈ។

**១.២.៣.៣.ពត៌មានមិនពិត**

ពត៌មានមិនពិត សំដៅទៅលើពត៌មានក្លែងក្លាយដែលខុសពីការពិត។ ពត៌មានមិនពិតអាចកើតមានឡើង ទោះបីជាអ្នកបង្ហាញពត៌មានមិនពិតមានចេតនា ឬ គ្មានចេតនាកុហក បោកប្រាស់ ឬ ក្លែងបន្លំអ្នកបង្ហាញឆន្ទៈក៏ដោយ។ ប៉ុន្តែ កាលណាអ្នកបង្ហាញព៌តមានមិនពិតមានចេតកុហក បោកប្រាស់ ឬ ក្លែងបន្លំ ការផ្តល់ព៌តមានមិនពិតបែបនេះនឹងប្រែក្លាយជាការឆបោកដូចដែលបានរៀបរាប់ខាងលើ។

ដោយផ្អែកលើមាត្រា ៣៤៨ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដើម្បីលុបចោលកិច្ចសន្យាដោយផ្អែកលើការផ្តល់ព៌តមានមិនពិត ត្រូវបំពេញលក្ខខណ្ឌដូចជា៖[44]

(១) ការបង្ហាញពត៌មានមិនពិតដោយភាគីនៃកិច្ចសន្យា គឺភាគីនៃកិច្ចសន្យាបានបង្ហាញពត៌មានក្លែងក្លាយដល់អ្នកបង្ហាញឆន្ទៈ ដោយសារតែការទទួល ឬ ការដឹងពត៌មានក្លែងក្លាយដូចគ្នា។

(២) ពុំចាំបាច់មានចេតនារបស់អ្នកបង្ហាញពត៌មានមិនពិតទេ គឺអ្នកបង្ហាញពត៌មានមិនពិតគ្មានចេតនាកុហក បោកប្រាស់ ក្លែងបន្លំដល់អ្នកបង្ហាញឆន្ទៈទេ។

[44] មេរៀនភាគ ១ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៣៤, ២០១៥។

(៣) ភាគីយល់ច្រឡំអង្គហេតុ គឺអ្នកបង្ហាញឆន្ទៈជឿជាក់ថា ពត៌មានមិនពិតគឺជាពត៌មានពិត ដោយយល់ឃើញខុសពីការពិតជាក់ស្តែង។

(៤) ភាគីនឹងមិនបង្ហាញឆន្ទៈទេបើមិនការយល់ច្រឡំ ភាគីនឹងមិនបង្ហាញឆន្ទៈទេបើមិនមានការយល់ច្រឡំ គឺដោយសារ តែការភាន់ច្រឡំតាមរយៈការទទួលពត៌មានមិនពិតដែលសំខាន់ ទៅលើចំណុចសំខាន់ក្នុងកិច្ចសន្យា ទើបអ្នកបង្ហាញឆន្ទៈយល់ព្រមបង្ហាញឆន្ទៈ តែបើមិនមានការភាន់ច្រឡំនោះទេ អ្នកបង្ហាញឆន្ទៈមិនបង្ហាញឆន្ទៈឡើយ ព្រោះខុសពីបំណងក្នុងការបង្កើតកិច្ចសន្យារបស់គាត់។

ការលុបចោលកិច្ចសន្យាដោយសារទទួលពត៌មានមិនពិត គឺចាំបាច់ត្រូវពិនិត្យទៅចេតនារបស់អ្នកបង្ហាញពត៌មានមិនពិត ព្រោះកាលណាតែអ្នកបង្ហាញពត៌មានមិនពិតមានចេតនាបង្ហាញពត៌មានមិនពិត សកម្មភាពនោះនឹងក្លាយទៅជាការឆបោកវិញ។ ម៉្យាងទៀតក្នុងករណីដែលអ្នកបង្ហាញឆន្ទៈ មានការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យាដោយសារតែការទទួលពត៌មានមិនពិត សកម្មភាពនោះអាចក្លាយទៅជាការភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា។ ការលុបចោលដោយឆបោក ឬ ការភាន់ចំណុចសំខាន់នៃកិច្ចសន្យា មិនត្រូវបានអនុញ្ញាតជានិច្ចកាលឡើយ លើកលែងតែបានបំពេញលក្ខខណ្ឌនៃការលុបចោលទាំងនេះ។ ហេតុនេះហើយទោះបីជាអ្នកបង្ហាញឆន្ទៈមិនមានលក្ខខណ្ឌគ្រាន់គ្រប់លុបចោលកិច្ចសន្យាដោយឆបោក ឬ ភាន់ច្រឡំចំណុចសំខាន់នៃកិច្ចសន្យា ក៏អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានដែរ ប្រសិនជាអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈដោយសារតែទទួលបានពត៌មានមិនពិតពីភាគីម្ខាងទៀត។

### ១.២.៣.៤.ការរំលោភបំពានលើស្ថានភាព

ការរំលោភលើស្ថានភាព កើតឡើងដោយសារមានភាពមិនស្មើគ្នារវាងភាគីនៃកិច្ចសន្យា លើឋានៈ ឬ ស្ថានភាពផ្សេងៗ ដូចជាស្ថានភាពសេដ្ឋកិច្ចឬតួនាទី មុខតំណែង ជាដើម។

ក្នុងការរំលោភលើស្ថានភាព ភាគីម្ខាងទៀតនៃកិច្ចសន្យាមិនបានប្រើប្រាស់នូវពាក្យសំដី ឬ កាយវិការណាមួយ ដើម្បីបំភិតបំភ័យអ្នកបង្ហាញឆន្ទៈឡើយ ប៉ុន្តែអ្នកបង្ហាញឆន្ទៈភ័យខ្លាចដោយសារតែភាគីម្ខាងទៀតមានតួនាទី ឋានៈ យសសក្តិខ្ពស់ជាងខ្លួន។

ដោយផ្អែកលើមាត្រា ៣៤៩ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដើម្បីលុបចោលកិច្ចសន្យាដោយផ្អែកលើការរំលោភលើស្ថានភាព ត្រូវបំពេញលក្ខខណ្ឌរួមមាន៖

(១) ការរំលោភបំពានដោយភាគីម្ខាងនៃកិច្ចសន្យាដែលឋានៈ ឬ ស្ថានភាពដែលមានអាទិភាពជាង គឺភាគីម្ខាងទៀតបានប្រើប្រាស់នូវឋានៈ ឬ ស្ថានភាពដែលមានអាទិភាពជាងខាងផ្នែកសង្គម អាចជាតួនាទី មុខតំណាង បទពិសោធន៍ខាងផ្នែកធ្វើជំនួញ ទៅលើអ្នកបង្ហាញឆន្ទៈ។

(២) ការប្រើប្រាស់ដោយមិនត្រឹមត្រូវនូវឋានៈ ឬ ស្ថានភាពពីភាគីម្ខាងដែលរំលោភបំពានកិច្ចសន្យា គឺជាការដែលភាគីម្ខាងទៀតនៃកិច្ចសន្យាប្រើប្រាស់ដោយមិនត្រឹមត្រូវនូវឋានៈដែលខ្លួនមានអាទិភាពជាងអ្នកបង្ហាញឆន្ទៈ ខាងផ្នែកសេដ្ឋកិច្ច ខាងផ្នែកសង្គម ឬបានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀត ទៅលើអ្នកបង្ហាញឆន្ទៈ។

(៣) ភាគីម្ខាងដែលបានរំលោភបំពានមានចេតនា គឺភាគីម្ខាងទៀតត្រូវតែមានចេតនាប្រើប្រាស់ឋានៈ ឬ ស្ថានភាពដែលខ្លួនមានអាទិភាពជាង គាបសង្កត់ទៅលើអ្នកបង្ហាញឆន្ទៈ ប៉ុន្តែបើភាគីម្ខាងគ្មានចេតនាប្រើប្រាស់ឋានៈ ឬ ស្ថានភាពដែលខ្លួនមានអាទិភាពជាងទេ ហើយអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈដោយការក្រែងចិត្ត ចង់ផ្គាប់ផ្គត់ ឬ ដោយសារសំលឹងឃើញផលប្រយោជន៍ផ្សេង នេះមិនមែនជាចេតនារបស់ភាគីម្ខាងនោះ។

(៤) អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈដោយការភ័យខ្លាច និងមិនអាចតបតបាន គឺភាគីម្ខាងទៀតនៃកិច្ចសន្យាបានបង្ខំដោយប្រយោល ដូចជាការដកចេញពីមុខតំណែង ការបញ្ឈប់មុខងារ ឬ ការផ្តាច់ជំនួញ របស់អ្នកបង្ហាញឆន្ទៈ ដែលធ្វើឲ្យអ្នកបង្ហាញឆន្ទៈមិនអាចប្រឆាំងតបតបាន ហើយមិនអាចបង្ហាញឆន្ទៈដោយសេរីព្រោះមានការភ័យខ្លាច។

### ១.២.៣.៥.ការគម្រាមកំហែង

ការគម្រាមកំហែង គឺជាការសំឡុតបំភ័យ ក្នុងគោលដៅឲ្យអ្នកបង្ហាញឆន្ទៈមានភាពភ័យខ្លាច តាមរយៈការប្រើប្រាស់ពាក្យសម្តី ឬ កាយវិការចំពោះអ្នកបង្ហាញឆន្ទៈផ្ទាល់ ញាតិរបស់អ្នកបង្ហាញឆន្ទៈ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងជាមួយអ្នកបង្ហាញឆន្ទៈ។ ។ ការគម្រាមកំហែងអាចប្រព្រឹត្តឡើងដោយភាគីផ្ទាល់ ឬ អាចប្រព្រឹត្តឡើងដោយតតិយជន។

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែង ពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈមានវិការៈ។[45] លក្ខខណ្ឌនៃការគម្រាមកំហែងមាន៖

(១) សកម្មភាពគម្រាមកំហែងដោយខុសច្បាប់ ដោយភាគី ឬដោយតតិយជន គឺជាសកម្មភាពដែលធ្វើឡើងដោយភាគីនៃកិច្ចសន្យា ឬ ដោយតតិយជន តាមរយៈពាក្យសម្តី កាយវិការ សារអេឡិចត្រូនិច ឬ សម្តែងចេញតាមលិខិត រូបភាព វត្ថុ ដើម្បីឲ្យអ្នកបង្ហាញឆន្ទៈមានការភ័យខ្លាចដោយសារតែការគម្រាមទាក់ទងនឹងជីវិត រាងកាយ ទ្រព្យសម្បត្តិ កិត្តិយស សេរីភាពជាដើម។

[45] មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

(២) ចេតនានៃការគម្រាមកំហែង គឺជាចេតនាគម្រាមរបស់ភាគីម្ខាងដើម្បីឲ្យអ្នកបង្ហាញឆន្ទៈ មានការភ័យខ្លាច ករណីខ្លះភាគីម្ខាងអាចមិនមានចេតនាទេ ប៉ុន្តែសកម្មភាពដែលភាគីម្ខាងបានធ្វើមើលទៅហាក់ដូចជាគម្រាមកំហែងតែគ្មានបំណងធ្វើឲ្យអ្នកបង្ហាញឆន្ទៈភ័យខ្លាច ដូចជាការបង្ហាញឲ្យអ្នកបង្ហាញឆន្ទៈដឹងថាខ្លួនមានភ្ជាប់អាវុធមកតាមជាមួយ មិនមែនជាចេតនានៃការគម្រាមកំហែង។

(៣) អ្នកបង្ហាញឆន្ទៈមានការភ័យខ្លាចចំពោះការគម្រាមកំហែង ប្រសិនបើការបង្ហាញឆន្ទៈរបស់អ្នកបង្ហាញឆន្ទៈ ធ្វើឡើងដោយឥទ្ធិពលអ្វីមួយធ្វើឲ្យមានការភ័យខ្លាច គឺជាការគម្រាមកំហែង ប៉ុន្តែប្រសិនបើអ្នកបង្ហាញឆន្ទៈមិនមានការភ័យខ្លាច ឬ ព្រួយបារម្ភចំពោះការគម្រាមកំហែងទេ ទោះបីជាភាគីម្ខាងម្ខាងទៀតបានគម្រាមកំហែងក៏ដោយ មិនមែនជាការគម្រាមកំហែងទេ ព្រោះមិនមានទំនាក់ទំនងរវាងការភ័យ និងការបង្ហាញឆន្ទៈរបស់អ្នកបង្ហាញឆន្ទៈទេ។

(៤) ការបង្ហាញឆន្ទៈដោយសារការគម្រាមកំហែង គឺអ្នកបង្ហាញឆន្ទៈយល់ព្រមក្នុងការបង្ហាញឆន្ទៈដោយសារការគម្រាមកំហែងរបស់ភាគីម្ខាងទៀត ឬ តតិយជន។ ការលុបចោលកិច្ចសន្យាដោយសារតែមានការគម្រាមកំហែងពីសំណាក់តតិយជន ទោះបីជាភាគីម្ខាងទៀតមិនបានដឹងអំពីការគម្រាមកំហែងក៏ដោយ ក៏អ្នកបង្ហាញឆន្ទៈដោយសារការគម្រាមកំហែងអាចលុបចោលកិច្ចសន្យាបានដែរ។

#### **១.២.៣.៦.ការកេងចំណេញហួសហេតុ**

ដើម្បីលុបចោលកិច្ចសន្យាដោយផ្អែកលើការកេងចំណេញហួសហេតុ ត្រូវបំពេញលក្ខខណ្ឌរួមមាន៖[46]

(១) ការឆ្លៀតឱកាសរបស់ភាគីទៀតនៃកិច្ចសន្យាចំពោះអ្នកបង្ហាញឆន្ទៈ គឺភាគីម្ខាងទៀតនៃកិច្ចសន្យាបានឆ្លៀតឱកាសដែលខ្លួនមានប្រៀប ដូចជាមុខតំណែង តួនាទី ជំនាញ ស្ថានភាព ទ្រព្យសម្បត្តិ ឬបច្ចេកទេសជាដើម ជាងអ្នកបង្ហាញឆន្ទៈ។

(២) ភាគីម្ខាងនៃកិច្ចសន្យាបានកេងចំណេញយ៉ាងសន្ធឹកសន្ធាប់ ពីព្រោះតែពាក្យថា «កេងចំណេញហួសហេតុ» គឺមានន័យខុសគ្នាទៅតាមស្ថានភាព កាលៈទេសៈ ពេលវេលា ទីតាំង ថាតើកម្រិតប៉ុណ្ណាទើបក្លាយជាអំពើកេងចំនេញហួសហេតុ? ជាធម្មតានៅក្នុងកិច្ចជំនួញជួញដូរ អាជីករតែងតែចង់លក់បានថ្លៃច្រើនទៅលើទំនិញ ដើម្បីចំណេញបានច្រើន ដូចនេះការលក់លើសពីតម្លៃទីផ្សារតិចតួចមិនមែនជាការកេងចំនេញហួសហេតុទេ ម៉្យាងទៀតប្រភេទទំនិញខ្លះលក់លើសពីតម្លៃទីផ្សារពីរដងក៏អាចបកស្រាយថាមិនមែនជាការកេងចំណេញ

[46] មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ហួសហេតុដែរ ប្រសិនជាទំនិញនោះមានតម្លៃតិចតួច ប៉ុន្តែបើចំពោះអចលវត្ថុ ឬ ចលវត្ថុដែលមានតម្លៃច្រើន ការលក់ទិញពីតម្លៃទីផ្សារ ពាក់កណ្ដាល ឬ ពីរដង អាចបកស្រាយបានថាជាការកេងចំណេញហួសហេតុ។

(៣) មានឆន្ទៈកេងយកចំណេញហួសហេតុ គឺភាគីម្ខាងមានឆន្ទៈបង្កើតកិច្ចសន្យាដោយឆ្លៀតឱកាសកេងយកចំនេញ ទៅលើអ្នកបង្ហាញឆន្ទៈ

(៤) អ្នកបង្ហាញឆន្ទៈ កំពុងជួបប្រទះការលំបាក ខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះបទពិសោធន៍ គឺភាគីម្ខាងទៀតបានប្រើប្រាស់ស្ថានភាពដែលអ្នកបង្ហាញឆន្ទៈកំពុងជួបប្រទះការលំបាក ខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះបទពិសោធន៍ ដែលធ្វើឲ្យអ្នកបង្ហាញឆន្ទៈមិនអាចប្រឆាំងតបតបានទេ។

ការកេងចំណេញហួសហេតុមិនពិចារណាអំពីអត្តនោម័តរបស់អ្នកបង្ហាញឆន្ទៈឡើយ គឺពិចារណាទៅលើផលចំណេញដែលភាគីទទួលបានប៉ុណ្ណោះ ។ ចំណុចដែលត្រូវបកស្រាយគឺត្រង់ចំណុចនេះហើយ ថាតើបែបណាទើបមានការកេងចំណេញហួសហេតុ? ការពិចារណានេះ គឺអាស្រ័យស្ថានភាពជាក់ស្ដែងនៃតម្លៃទំនិញ ឬ វត្ថុនោះ ដូចជា ទឹកសុទ្ធតម្លៃលើទីផ្សារលក់រាយគឺមួយដប ១០០០៛ ហើយបើលក់នៅតាមភោជនីយ៍ដ្ឋាន ឬ ទីកន្លែងកំសាន្តខ្លះអាចមានតម្លៃដល់ទៅ ៤០០០៛ តើនេះជាការកេងចំណេញហួសហេតុទេ? ចំពោះតម្លៃទឹកសុទ្ធ ៤០០០៛ នេះមិនចាត់ទុកជាការកេងចំណេញហួសហេតុទេ ព្រោះតម្លៃ ៤០០០៛ មិនមែនជាចំនួនច្រើនសន្ធាប់សន្ធឹកទេ។

# ជំពូកទី២
# វិធីនៃការលុបចោលកិច្ចសន្យា

## ២.១.អ្នកមានសិទ្ធិលុបចោល

ការលុបចោលកិច្ចសន្យា មិនមែនបុគ្គលណាក៏អាចលុបចោលកិច្ចសន្យាតាមតែអំពើចិត្តបាននោះទេ ព្រោះកិច្ចសន្យាដែលអាចលុបចោលបាន មានអានុភាពតែចំពោះភាគីនៃកិច្ចសន្យា និងបុគ្គលដែលពាក់ព័ន្ធផលប្រយោជន៍នៃកិច្ចសន្យាតែប៉ុណ្ណោះ។ ដូចនេះហើយ ទើបក្រមរដ្ឋប្បវេណីបានកំណត់យ៉ាងច្បាស់ពីអ្នកដែលមានសិទ្ធិលុបចោលដោយផ្អែកលើមូលហេតុនៃការលុបចោលកិច្ចសន្យា។

### ២.១.១.អ្នកមានសិទ្ធិលុបចោលកិច្ចសន្យាករណីកិច្ចសន្យាមានវិការៈ

អ្នកដែលមានសិទ្ធិលុបចោលចំពោះសកម្មភាពដែលអាចលុបចោលបាន ដោយមូលហេតុថាមានវិការៈក្នុងការបង្ហាញឆន្ទៈដែលរួមមានការភាន់ច្រឡំការឆបោក ការផ្តល់ព័តមានមិនពិត ការរំលោភលើស្ថានភាព ការគម្រាមគំហែង និងអំពើកេងយកចំណេញហួសហេតុមានដូចជា៖[47]

- អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ គឺជាសាមីខ្លួនផ្ទាល់ដែលបានបង្កើតកិច្ចសន្យាដោយមានវិការៈ។
- អ្នកតំណាងដែលច្បាប់បានកំណត់ គឺជាអ្នកតំណាងដែលបានទទួលសិទ្ធិដោយយោងទៅតាមបញ្ញត្តិច្បាប់ ឬ សេចក្តីសម្រេចរបស់តុលាការ អាចជាឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ អ្នកអាណាព្យាបាលទូទៅ ជាដើម។
- សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ គឺជាជនដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចរបស់អ្នកបង្ហាញឆន្ទៈ តាមរយៈសន្តតិកម្ម។ អ្នកទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ គឺជាជនដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចរបស់អ្នកបង្ហាញឆន្ទៈ តាមរយៈអានុភាពនៃអនុប្បទានឋានៈក្នុងកិច្ចសន្យា។
- អ្នកទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ គឺជាជនដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចរបស់អ្នកបង្ហាញឆន្ទៈតាមរយៈអានុភាពនៃអនុប្បទានឋានៈក្នុងកិច្ចសន្យា។
- អច្ច័យលាភីសកល[48] ពីអ្នកដែលបង្ហាញឆន្ទៈមានវិការៈ នៅក្នុងមាត្រា ៣៥៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីមិនបានចែងពី អច្ច័យលាភីសកលទេ ប៉ុន្តែកាលដែលអច្ច័យលាភីសកលពីអ្នកដែលបង្ហាញ

[47] មាត្រា ៣៥៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[48] មាត្រា ១២១២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ឆន្ទៈមានវិការៈ អាចលុបចោលកិច្ចសន្យាបាន ដោយសារតែអច្ច័យលាភីមានសិទ្ធិ និងករណីយកិច្ចដូចគ្នាទៅនឹងសន្តតិជន។

### ២.១.២.អ្នកមានសិទ្ធិលុបចោលករណីកិច្ចសន្យាធ្វើឡើងដោយខ្វះសមត្ថភាព

ពាក្យសមត្ថភាពក្នុងការបង្ហាញឆន្ទៈ គឺមានអត្ថន័យដូចគ្នាទៅនឹងពាក្យ សមត្ថភាពនៃឆន្ទៈដែលបានចែងនៅក្នុងមាត្រា ១៤ នៃក្រមរដ្ឋប្បវេណីនេះ។[49]

អ្នកដែលមានសិទ្ធិលុបចោល ចំពោះកិច្ចសន្យាដែលធ្វើឡើងដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ឬ ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពមានដូចជា៖[50]

- អ្នកបង្ហាញឆន្ទៈ គឺសំដៅទៅលើសាមីខ្លួនដែលត្រូវបានកម្រិតសមត្ថភាពបានបង្ហាញឆន្ទៈ ដូចជា អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។ ជនដែលត្រូវបានកម្រិតសមត្ថភាព អាចអនុវត្តនូវសិទ្ធិលុបចោលដោយឯករាជ្យបាន ប៉ុន្តែក្រោយពីបានអនុវត្តសិទ្ធិលុបចោលហើយ ជននោះមិនអាចលុបចោលនូវសិទ្ធិលុបចោលនោះបានឡើយ។[51]
- អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកបង្ហាញឆន្ទៈ គឺជាអ្នកតំណាងដែលបានទទួលសិទ្ធិដោយយោងទៅតាមបញ្ញត្តិច្បាប់ ឬ សេចក្តីសម្រេចរបស់តុលាការ អាចជាឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ អ្នកអាណាព្យាបាលទូទៅ ជាដើម។
- ហិតូបត្ថម្ភកៈនៃអ្នកបង្ហាញឆន្ទៈ ហិតូបត្ថម្ភកៈនៃអ្នកបង្ហាញឆន្ទៈ គឺជាជនដែលតុលាការចាត់តាំងឲ្យអនុវត្តការគ្រប់គ្រងលើហិតូបត្ថម្ភដែលជាអ្នកបង្ហាញឆន្ទៈ។
- សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈ គឺជាជនដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចរបស់អ្នកបង្ហាញឆន្ទៈ តាមរយៈសន្តតិកម្ម។ អ្នកទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ គឺជាជនដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចរបស់អ្នកបង្ហាញឆន្ទៈ តាមរយៈអានុភាពនៃអនុប្បទានឋានក្នុងកិច្ចសន្យា។
- អច្ច័យលាភីសកលរបស់អ្នកបង្ហាញឆន្ទៈ គឺជាបុគ្គលដែលទទួលអច្ច័យទាន ហើយអច្ច័លាភីសកលរបស់អ្នកបង្ហាញឆន្ទៈ មានសិទ្ធិ និងករណីយកិច្ចដូចគ្នាទៅនឹងសន្តតិជន។

[49] មេរៀនភាគ ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៧, ២០១៦។

[50] មាត្រា ៣៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[51]មេរៀនភាគ ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៨, ២០១៦។

- អ្នកដែលទទួលឋានៈបន្តក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈ នៅក្នុងបញ្ញត្តិនៃមាត្រា ៣៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី មិនបានកំណត់អំពីអ្នកដែលទទួលឋានៈបន្តក្នុងកិច្ចសន្យាពីអ្នកបង្ហាញឆន្ទៈទេ ប៉ុន្តែបើតាមគោលគំនិតរបស់មាត្រា ៥១៤ នៃក្រមរដ្ឋប្បវេណី អ្នកដែលទទួលឋានៈបន្តក្នុងកិច្ចសន្យាក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។

## ២.២.វិធីនៃការលុបចោលកិច្ចសន្យា

ការលុបចោលកិច្ចសន្យា ធ្វើឡើងតាមរយៈការជូនដំណឹងទៅភាគីម្ខាងទៀតនៃកិច្ចសន្យា។ អនុភាពនៃការលុបចោល ត្រូវកើតឡើងនៅពេលដែលដំណឹងនោះ បានទៅដល់ភាគីម្ខាងទៀត។[52]

ឆ្លងតាមន័យខាងលើ ការលុបចោលមិនបាច់ធ្វើតាមរយៈតុលាការទេ។ ភាគច្រើនការលុបចោលធ្វើឡើងដោយការផ្ញើរលិខិតជូនដំណឹងអំពីការបង្ហាញឆន្ទៈលុបចោលទៅភាគីម្ខាងទៀត ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងភាគីអាចធ្វើតាមវិធីណាក៏បាន ឲ្យតែការបង្ហាញឆន្ទៈនោះបានទៅដល់ភាគីម្ខាងទៀត។[53] មានន័យថាភាគីអាចអនុវត្តសិទ្ធិលុបចោលតាមរយៈតុលាការក៏បាន ឬ ក្រៅប្រព័ន្ធតុលាការក៏បាន។

ការលុបចោលកិច្ចសន្យាមិនធ្វើតាមរយៈតុលាការ ដោយសារបច្ចុប្បន្នបច្ចេកវិទ្យាកាន់តែទំនើបគេអាចប្រើមធ្យោបាយងាយស្រួលដូចជា ជូនដំណឹងតាមរយៈការទូរស័ព្ទទៅប្រាប់ ការផ្ញើរសារអេឡិចត្រូនិច ដូចជាFacebook E-mail Line Telegram... ជាដើម។ នៅពេលដែលភាគីប្រើប្រាស់មធ្យោយបាយជូនដំណឹងតាមរយៈការផ្ញើរសារអេឡិចត្រូនិច ភាគីត្រូវប្រាកដថាការជូនដំណឹងរបស់ខ្លួនពិតជាបានទៅដល់ភាគីម្ខាងទៀតមែន ព្រោះការប្រើប្រាស់មធ្យោយបាយនេះ អាចមានករណីខ្លះមិនអាចបញ្ជូនដំណឹងទៅភាគីម្ខាងទៀតបាន។ ប៉ុន្តែប្រសិនជាអ្នកបង្ហាញឆន្ទៈលុបចោលអះអាងថាខ្លួនពិតជាបានជូនដំណឹងទៅភាគីម្ខាងទៀត តាមរយៈទូរស័ព្ទ តាមការផ្ញើរសារអេឡិចត្រូនិច ឬ តាមរយៈសំបុត្រហើយ តែភាគីម្ខាងទៀតបដិសេធការអះអាងរបស់អ្នកបង្ហាញឆន្ទៈថាខ្លួនមិនបានទទួលការជូនដំណឹងទេ វានឹងបង្កការពិបាកក្នុងការពិចារណាថាភាគីទៀតបានដឹង ឬ មិនដឹងពីការលុបចោលកិច្ចសន្យារបស់អ្នកបង្ហាញឆន្ទៈលុបចោល។ ប៉ុន្តែចៀសវាងករណីមានវិវាទ ភាគីគប្បីប្រើប្រាស់វិធីណាដែលងាយស្រួលបង្ហាញអំពីការជូនដំណឹងដល់ភាគីម្ខាងទៀតដើម្បីទុកជាភស្តុតាង ដូចជាឲ្យភាគីម្ខាងទៀតផ្តិតមេដៃ ចុះហត្ថលេខា ឬ ថតទុកសារអេឡិចត្រូនិច ដែលបង្ហាញថាភាគីម្ខាងទៀតបានទទួលដំណឹងពិតប្រាកដមែន។ ដើម្បីជាសំអាងបញ្ជាក់កាន់តែច្បាស់ពីការជូនដំណឹងទៅអំពីការបង្ហាញឆន្ទៈទៅកាន់ភាគីម្ខាង

[52] មាត្រា ៣៦០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[53] មេរៀនភាគ ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៥, ២០១៦។

ទៀតដែលនៅឆ្ងាយ អាចប្រើមធ្យោបាយ "ការផ្តល់ដំណឹងឆ្លើយតបពីការបានទទួល" នៃលិខិតអនុសិដ្ឋដែលមាន "ការផ្តល់ដំណឹងឆ្លើយតបពីការទទួល" និងឯកសារចម្លងនៃលិខិតដែលបានចុះនិទ្ទេសដោយក្រឡាបញ្ជីតុលាការ។[54] ម៉្យាងទៀត អ្នកបង្ហាញឆន្ទៈលុបចោលអាចប្រើប្រាស់វិធីណាដែលងាយស្រួលបង្ហាញអំពីការជូនដំណឹងដល់ភាគីម្ខាងទៀត ដើម្បីទុកជាភស្តុតាង ដូចជាឲ្យភាគីម្ខាងទៀតផ្តិតមេដៃ ចុះហត្ថលេខា ឬ ថតទុកសារអេឡិចត្រូនិចទុក ដែលបង្ហាញថាភាគីម្ខាងទៀតបានទទួលដំណឹងពិតប្រាកដមែន។

ក្នុងករណីដែលអ្នកសិទ្ធិលុបចោលចង់អនុវត្តសិទ្ធិលុបចោលតាមរយៈតុលាការ អ្នកមានសិទ្ធិលុបចោលអាចធ្វើបណ្តឹងទាមទារឲ្យរលត់ទំនាក់ទំនងគតិយុត្ត ជាបណ្តឹងទាមទារឲ្យតុលាការចេញសាលក្រមប្រកាសជាថ្មីនូវទំនាក់ទំនងគតិយុត្ត ដោយផ្អែកលើមូលហេតុនៃសិទ្ធិលុបចោល ដែលជាការទាមទារតាមផ្លូវបណ្តឹង។

## ២.៣.អាជ្ញាយុកាលនៃការរលត់សិទ្ធិលុបចោល

### ២.៣.១.និយមន័យនៃអាជ្ញាយុកាលនៃការរលត់សិទ្ធិលើមំណុល

អាជ្ញាយុកាល គឺជាអំឡុងពេលមួយដែលកំណត់ដោយច្បាប់។ ការកន្លងហួសនៃអំឡុងពេលនេះ បង្កើតឲ្យមានអានុភាពនៃលទ្ធកម្ម ឬ ការលត់សិទ្ធិណាមួយ។[55]

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល គឺជាប្រព័ន្ធដែលផ្តល់ការពារនូវស្ថេរភាពតាមផ្លូវច្បាប់ ចំពោះស្ថានភាពពិតជាក់ស្តែង ដែលបានបន្តរយៈពេលយូរ នាំឲ្យអ្នកមានសិទ្ធិលុបចោលដែលមិនត្រូវបានអនុវត្តរយៈពេលយូរនឹងត្រូវបាត់បង់សិទ្ធិ ពោលគឺ រំលត់សិទ្ធិលុបចោលដោយផ្អែកលើករណីដែលអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិក្នុងកំឡុងពេលដែលត្រូវបានកំណត់។

ម៉្យាងទៀត បញ្ញត្តិស្តីការផ្អាកអាជ្ញាយុកាលមិនត្រូវយកមកអនុវត្តឡើយ [56] ដើម្បីឲ្យទំនាក់ទំនងដែលគ្មានស្ថិរភាពមានស្ថិរភាពឡើងវិញ ហើយជម្រុញឲ្យអ្នកមានសិទ្ធិលុបចោលអនុវត្តសិទ្ធិលុបចោលរបស់ខ្លួនកាន់តែឆាប់រហ័ស។

ក្រោយពេលផុតអាជ្ញាយុកាល ជនដែលមានសិទ្ធិលុបចោលមិនអាចលុបចោលកិច្ចសន្យាដែលអាចលុបចោលបានទៀតទេ ដូច្នោះកិច្ចសន្យាត្រូវបានចាត់ទុកថាមានសុពលភាពស្ថាពរ។[57]

---

[54] មាត្រា ៧ កថាខណ្ឌ១ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី,លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។

[55] សន្ទានុក្រម ផ្នែករដ្ឋប្បវេណី ចំណុច១៩៦។

[56] មាត្រា ៣៦៣ កថាខណ្ឌ១ វាក្យខណ្ឌ២ នៃក្រមរដ្ឋប្បវេណី។

### ២.៣.២.លក្ខខណ្ឌនៃអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល

#### ២.៣.២.១.ករណីដែលអ្នកមានសិទ្ធិលុបចោលបានដឹង

សិទ្ធិលុបចោល នឹងរលត់ បើអ្នកមានសិទ្ធិលុបចោលមិនប្រើសិទ្ធិក្នុងរយៈពេល ៣ ឆ្នាំ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន។[58]

សច្ចានុមតិ គឺជាការយល់ព្រមទទួលស្គាល់ដែលមានអានុភាពប្រតិសកម្ម។[59] នៅពេលដែលអ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិ គឺជាពេលដែលបានដឹងថាសកម្មភាពរបស់ខ្លួនអាចលុបចោលបាន ដោយផ្អែកលើបុរេលក្ខខណ្ឌការលុបចោល។

ករណីការលុបចោលដោយមូលហេតុវិការៈនៃការបង្ហាញឆន្ទៈ ឬ គ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ពេលដែលអាចផ្តល់សច្ចានុមតិបាន គឺជាពេលដែលអ្នកមានសិទ្ធិលុបចោលបានដឹងអំពីមូលហេតុនៃការលុបចោល។

ករណីការលុបចោលដោយមូលហេតុក្នុងការកម្រិតសមត្ថភាព ជនដែលត្រូវបានកម្រិតសមត្ថភាព អាចផ្តល់សច្ចានុមតិបាននៅពេល សមត្ថភាពដែលត្រូវកម្រិតរបស់ជននោះ បានត្រឡប់មកភាពដើមវិញ។ ទន្ទឹមនឹងនេះដែរ ចំពោះអ្នកអាណាព្យាបាលចំពោះជនដែលត្រូវបានកម្រិតសមត្ថភាព ផ្តល់ដែលអាចផ្តល់សច្ចានុមតិបានត្រូវបានគណនា ពីអ្នកអាណាព្យាបាលបានដឹងអំពីមូលហេតុនៃការលុបចោល។

ម្យ៉ាងទៀត ក្នុងករណីប្រសិនបើតាវកាលិក ត្រូវបានប្រគល់រួចហើយ អ្នកដែលមានសិទ្ធិលុបចោល អាចទាមទារឲ្យសងសេចក្តីចម្រើនឥតហេតុ ដែលកើតឡើងដោយសារការលុបចោលនោះ ដោយរយៈពេលនៃការទាមទារនេះអនុវត្តដូចគ្នានឹងការអនុវត្តសិទ្ធិលុបចោលដែរ គឺមានរយៈពេល៣ឆ្នាំ បន្ទាប់ពីអ្នកមានសិទ្ធិលុបចោលបានដឹងថាខ្លួនមានសិទ្ធិលុបចោល ពោលគឺបើអ្នកសិទ្ធិលុបចោល បានលុបចោលកិច្ចសន្យានៅឆ្នាំទី២ នោះសិទ្ធិទាមទារឲ្យសងដោយសេចក្តីចម្រើនឥតហេតុនឹងរលត់នៅឆ្នាំទី៥។

#### ២.៣.២.២.ករណីដែលអ្នកមានសិទ្ធិលុបចោលមិនបានដឹង

ទោះបីជាអ្នកដែលមានសិទ្ធិលុបចោលមិនបានដឹងក៏ដោយ ប្រសិនជាហួសរយៈពេល ១០ ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃកិច្ចសន្យា នោះសិទ្ធិលុបចោលក៏ត្រូវរលត់ដែរ។[60] មានន័យថាអាជ្ញាយុកាលនៃការរលត់

[57] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ១-៣, ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ភ្នំពេញ, ទំព័រ ១១៣, ២០១៧។

[58] មាត្រា ៣៦៣ កថាខណ្ឌ១ វាក្យខណ្ឌ១ នៃក្រមរដ្ឋប្បវេណី។

[59] សន្ទានុក្រម ផ្នែកក្រមរដ្ឋប្បវេណី ចំណុច១៤២។

សិទ្ធិលុបចោលនឹងត្រូវបានផុតរលត់ចាំងតាំងពីកាលបរិច្ឆេទនៃថ្ងៃដែលកិច្ចសន្យាត្រូវបានបង្កើត ហួសរយៈពេល ១០ឆ្នាំ ទោះបីជាអ្នកមានសិទ្ធិលុបចោលបានអះអាងថាខ្លួនមិនបានដឹងពីបុរេលក្ខខណ្ឌការលុបចោល ក៏អាជ្ញាយុកាលនៃការរលត់សិទ្ធិលុបចោលនឹងត្រូវរលត់ដោយស្វ័យប្រវត្តិ។ អំឡុងពេល១០ឆ្នាំ ដែលច្បាប់បានទទួលស្គាល់ការលុបចោលគឺជាអំឡុងមួយដល់យូរហើយ ដូច្នោះបើហួសអំឡុងពេល ១០ឆ្នាំហើយមិនបាច់ទទួលស្គាល់សិទ្ធិលុបចោលទៀតទេ ព្រោះអំឡុងពេលនេះកម្មវត្ថុអាចនឹងត្រូវបានចាត់ចែងច្រើនដង ហើយបើនៅតែទទួលសិទ្ធិលុបចោលទៀត នឹងបង្កឲ្យមានភាពស្មុគស្មាញជាមិនខាន។

ក្នុងករណីប្រសិនបើតាវកាលិក ត្រូវបានប្រគល់រួចហើយ អ្នកដែលមានសិទ្ធិលុបចោល អាចទាមទារឲ្យសងសេចក្តីចម្រើនឥតហេតុ ដែលកើតឡើងដោយសារការលុបចោលនោះ ដោយរយៈពេលនៃការទាមទារនេះ គឺមានរយៈពេល៣ឆ្នាំ បន្ទាប់ពីអ្នកមានសិទ្ធិដែលមិនបានដឹងថាខ្លួនមានលុបចោល បានដឹងអំពីមូលហេតុនៃការលុបចោល ពោលគឺបើអ្នកមានសិទ្ធិលុបចោល លុបចោលកិច្ចសន្យានៅឆ្នាំទី៨ បន្ទាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យា នោះសិទ្ធិទាមទារឲ្យសងដោយសេចក្តីចម្រើននឹងរលត់នៅឆ្នាំទី១២។ ករណីដែលមានបុគ្គលច្រើននាក់មានសិទ្ធិលុបចោល បញ្ញត្តិនៃកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រា ៣៦៣ នៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្ត ចំពោះសិទ្ធិលុបចោលនីមួយៗ ពោលគឺសិទ្ធិលុបចោលរបស់បុគ្គលម្នាក់ៗ ត្រូវរលត់រៀងៗខ្លួន។

[60] មាត្រា ៣៦៣ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី។

# ជំពូកទី៣
# អានុភាពនៃការលុបចោលកិច្ចសន្យា

## ៣.១.អានុភាពនៃការលុបចោលចំពោះភាគី

កិច្ចសន្យាមួយមានសុពលភាព គឺអនុវត្តបាន តែប្រសិនបើកិច្ចសន្យានោះត្រូវបានអ្នកមានសិទ្ធិលុបចោល តើអានុភាពនៃការលុបចោល មានអានុភាពយ៉ាងណាខ្លះ ចំពោះគូភាគីនៃកិច្ចសន្យា?

ការលុបចោល មានភាពដូចគ្នាទៅនឹងមោឃភាពមិនដាច់ខាត នេះបើប្រៀបធៀបទៅនឹងក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា។

នៅពេលដែលភាគីនៃកិច្ចសន្យាបានលុបចោលកិច្ចសន្យា លទ្ធផលនៃការលុបចោលកិច្ចសន្យា គឺក្នុងករណីដែលភាគីមិនទាន់អនុវត្តកិច្ចសន្យានោះកាតព្វកិច្ចរបស់ភាគីនឹងត្រូវរលត់ ហើយក្នុងករណីដែលភាគីបានអនុវត្តកិច្ចសន្យាហើយ ភាគីដែលបានទទួលការផ្តល់តាវកាលិក ត្រូវប្រគល់ត្រឡប់ទៅឲ្យភាគីម្ខាងទៀត តាមគោលការណ៍នៃសេចក្តីចម្រើនឥតហេតុ។

### ៣.១.១.ករណីដែលភាគីមិនទាន់អនុវត្តកិច្ចសន្យា

កិច្ចសន្យាដែលអាចលុបចោលបានមានសុពលភាព រហូតដល់ពេលអ្នកដែលមានសិទ្ធិលុបចោល លុបចោលកិច្ចសន្យា។[61] មានន័យថា កិច្ចសន្យានៅតែមានសុពលភាព ប្រសិនជាអ្នកមានសិទ្ធិលុបចោល មិនបានលុបចោលកិច្ចសន្យា។

ផ្ទុយទៅវិញ ប្រសិនបើអ្នកមានសិទ្ធិលុបចោល បានលុបចោលកិច្ចសន្យា កិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។[62] មានន័យថា ប្រសិនបើអ្នកមានសិទ្ធិលុបចោលបានបង្ហាញឆន្ទៈលុបចោលកិច្ចសន្យា នោះកិច្ចសន្យានឹងគ្មានអានុភាពតាំងពីបង្កើតមកម្ល៉េះ។

ប្រសិបើអ្នកមានសិទ្ធិលុបចោលមិនទាន់បានអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅឡើយ នោះកាតព្វកិច្ចដែលត្រូវអនុវត្តរបស់ភាគីនឹងត្រូវរលត់ ពោលគឺភាគីមិនចាំបាច់អនុវត្តកាតព្វកិច្ចទេ ហើយកាតព្វកិច្ច និងសិទ្ធិដែលមានក្នុងកិច្ចសន្យាត្រូវចាត់ទុកថាគ្មានតាំងពីដំបូងដែរ។ នេះជាអានុភាពប្រតិសកម្មនៃការលុបចោលកិច្ចសន្យា។

---

[61] មាត្រា ៣៥៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

[62] មាត្រា ៣៥៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

### ៣.១.២.ករណីដែលភាគីបានអនុវត្តកិច្ចសន្យា

ក្នុងករណីភាគីនៃកិច្ចសន្យាបានអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា ដោយមានការផ្តល់តាវកាលិក នោះភាគីដែលបានផ្តល់តាវកាលិកអាចទាមទារតាវកាលិកមកវិញ តាមរយៈការអនុវត្តសិទ្ធិទាមទារដោយផ្អែកលើកម្មសិទ្ធិ ឬ សេចក្តីចម្រើនដោយឥតហេតុ។

តាវកាលិក គឺជាវត្ថុ ឬសកម្មភាព ដែលជាទីតាំង(ឬជាកម្មវត្ថុ) នៃកាតព្វកិច្ច។[63]

ក្នុងករណីដែលមានការលុបចោលកិច្ចសន្យា កិច្ចសន្យានឹងពុំមានអានុភាព ឬ បាត់បង់អានុភាព នោះភាគីដែលបានផ្តល់តាវកាលិក អាចទាមទារតាវកាលិករបស់ខ្លួនវិញតាមរយៈសិទ្ធិទាមទារឲ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ។ កម្មសិទ្ធិករអាចទាមទារឲ្យអ្នកកាន់កាប់ប្រគល់វត្ថុរបស់ខ្លួនវិញបាន[64] ព្រោះអ្នកកាន់កាប់មិនមានមូលហេតុគតិក្នុងការកាន់កាប់ដោយសារតែកិច្ចសន្យាត្រូវបានលុបចោល។

មួយវិញទៀតក្នុងករណីទាមទារឲ្យសងតាវកាលិកដោយផ្អែកទៅលើសេចក្តីចម្រើនឥតហេតុវិញ ភាគីម្ខាងទៀតដែលបានទទួលតាវកាលិកពីកិច្ចសន្យានឹងគ្មានមូលហេតុក្នុងការទទួលប្រយោជន៍ ដែលក្លាយទៅជាសេចក្តីចម្រើនដោយឥតហេតុដែលតម្រូវឲ្យភាគីម្ខាងទៀតនៃការលុបចោលកិច្ចសន្យា មានករណីយកិច្ចប្រគល់នូវតាវកាលិកទៅឲ្យអ្នកលុបចោលត្រឹមកម្រិតផលប្រយោជន៍នៅមាន។[65] ប៉ុន្តែបើភាគីម្ខាងទៀតនៃការលុចោលកិច្ចសន្យាដែលទទួលបានផលប្រយោជន៍មានចេតនា ឬ មានកំហុស ចំពោះកិច្ចសន្យា ដោយធ្វើឲ្យកិច្ចសន្យាបាត់បង់អានុភាព ភាគីម្ខាងទៀតនៃការលុចោលកិច្ចសន្យាមានករណីយកិច្ចត្រូវសងផលប្រយោជន៍នៅពេលបានដឹងដោយភ្ជាប់ជាមួយការប្រាក់។[66]

ការប្រាក់នេះ ត្រូវគិតអត្រាការប្រាក់ចំនួន ៥ ភាគរយក្នុងមួយឆ្នាំ។[67]

លើសពីនេះទៅទៀត បើបុគ្គលដែលបាត់បង់ផលប្រយោជន៍បានទទួលការខូចខាត បុគ្គលដែលទទួលផលប្រយោជន៍ត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាត។[68]

[63] សន្ទានុក្រម ផ្នែករដ្ឋប្បវេណី ចំណុច១៩៦។

[64] មាត្រា ១៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

[65] មាត្រា ៧៣៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

[66] មាត្រា ៧៣៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

[67] មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី។

[68] មាត្រា ៧៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។

## ៣.២.អានុភាពនៃការលុបចោលចំពោះតតិយជន

ការលុបចោលមិនត្រឹមតែមានអានុភាពចំពោះគូភាគីប៉ុណ្ណោះទេ គឺអានុភាពចំពោះតតិយជនដែរ ក្នុងករណីដែលភាគីម្ខាងបានផ្ទេរតាវកាលិកកិច្ចសន្យាដែលបានលុបចោលទៅតតិយជន។

តតិយជន សំដៅដល់ជនទីបី ឬ ជនដែលមិនមែនជាភាគីនៅក្នុងទំនាក់ទំនងគតិយុត្ត។[69] ម្យ៉ាងទៀតដោយផ្អែកតាមរយៈការបកស្រាយនៅប្រទេសជប៉ុន តតិយជន គឺជាជនទីបីក្រៅពីភាគី និងសន្តតិជនរបស់ភាគីដែលពាក់ពន្ធ ហើយមានទំនាស់ផលប្រយោជន៍ សិទ្ធិផ្ទុយពីបុគ្គល ដែលទាមទារឲ្យលុបចោលដោយមូលហេតុវិការៈនៃការបង្ហាញឆន្ទៈ។[70]

មានគំនិតពីរដែលទាក់ទងនឹងអត្ថន័យនៃពាក្យ តតិយជន៖

-**គំនិតទី១**: តតិយជន សំដៅទៅលើជនដែលមានផលប្រយោជន៍ស្របច្បាប់អំពីការលុបចោលកិច្ចសន្យា។ ដើម្បីធ្វើឲ្យមានតុល្យភាពផលប្រយោជន៍រវាងភាគីដែលលុបកិច្ចសន្យា និងតតិយជន ពេលតតិយជន គឺត្រូវបានគេកម្រិតត្រឹមជនដែលមានផលប្រយោជន៍ប៉ុណ្ណោះ។ តតិយជន ដែលមិនបានចុះបញ្ជីនូវប្រតិបត្តិការលក់ទិញរបស់ខ្លួន នៅមុនពេលលុបចោលមិនបានបំពេញនូវលក្ខខណ្ឌបែបនេះទេ ព្រោះកម្មសិទ្ធិ មិនទាន់ផ្ទេរឡើយប្រសិនបើមិនបានចុះបញ្ជី[71] ដោយមិនគិតពីការលុបចោលរបស់ «ក» ទេ។ ជាសេចក្តីសន្និដ្ឋាន គំនិតទី១ គិតថា «គ» មិនមែនជាតតិយជនទេ ហើយ «ក» អាចអះអាងការលុបចោលរបស់ខ្លួន ចំពោះ «គ» បាន។

-**គំនិតទី២**: តតិយជន សំដៅមនុស្សគ្រប់រូប លើកលែងតែភាគីនៃកិច្ចសន្យា ដែលបានលុបចោល។ ផ្អែកទៅតាមគំនិតទី២នេះ «គ» គឺជាតតិយជន ដូច្នោះ «ក» មិនអាចអះអាចការលុបចោលចំពោះ «គ» បានទេ។

នៅក្នុងក្រុមការងារមានសមាជិក ៧រូប គាំទ្រគំនិតទី២ និងសមាជិក ៤រូបផ្សេងទៀតគាំទ្រគំនិតទី១។[72] តាមទ្រឹស្តីអ្នកច្បាប់មួយចំនួនយល់ថា បញ្ញត្តិដែលមានចែងនៅក្នុងមាត្រា ៣៦៤ កថាខណ្ឌទី ៤ មិនមែនតែការពារតតិយជនមុនការលុបចោលកិច្ចសន្យាទេ តតិយជនក្រោយពេលលុបចោលក៏ត្រូវបានការពារដែរ។ មានន័យថាពាក្យ "**តតិយជន**" នៅក្នុងមាត្រានេះ សំដៅទាំងតតិយជនមុនការលុបចោល និងតតិយជនក្រោយពេលលុបចោល។[73]

---

[69] សន្ធានុក្រម ផ្នែករដ្ឋប្បវេណី ចំណុច៤៨។

[70] សៀវភៅ កម្រងមេរៀនវិភាគទានច្បាប់, ទំព័រ ១៦៣, ឆ្នាំ២០១៨។

[71] មាត្រា ១៣៥ នៃក្រមរដ្ឋប្បវេណី។

[72] មេរៀនភាគ ១ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៦៥-៦៦, ២០១៥។

[73] មេរៀនភាគ ១ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៥, ២០១៥។

អ្នកច្បាប់ភាគច្រើនបានលើកឡើងនូវស្ថានភាពរបស់តតិយជនពីរផ្សេងគ្នា គឺ តតិយជនមុនការលុបចោល និងតតិយជនក្រោយការលុបចោល។ ការបែងចែកយ៉ាងនេះដោយសារតែសិទ្ធិរបស់តតិយជនមុនការលុបចោល និងក្រោយការលុបចោល មានលក្ខណៈខុសគ្នា ហើយអាចទទួលបានការការពារតាមរយៈប្រព័ន្ធខុសពីគ្នា។

### ៣.២.១.តតិយជនមុនការលុបចោល

តតិយជនមុនការលុបចោល ជាតតិយជនដែលបានទទួលសិទ្ធិបន្តពីភាគីម្ខាងទៀតមុនការលុបចោលកិច្ចសន្យា ពោលគឺ តតិយជនប្រភេទនេះទទួលបានការប្រគល់សិទ្ធិពីបុគ្គលដែលមានសិទ្ធិចំពោះតាវកាលិក។

តតិយជនមុនការលុបចោលកិច្ចសន្យា បានទទួលរងការខូចខាតដោយសារតែអនុភាពប្រតិសកម្មនៃការលុបចោល គឺគាត់បានបង់បាត់សិទ្ធិ ឬកម្មវត្ថុនៃកិច្ចសន្យានៃកិច្ចសន្យាដោយសារតែអានុភាពប្រតិសកម្មនៃការលុបចោលកិច្ចសន្យារវាងភាគីម្ខាង និងភាគីម្ខាងទៀតដែលគាត់បានបង្កើតកិច្ចសន្យាជាមួយ។

តតិយជនមុនការលុបចោលកិច្ចសន្យា ត្រូវបានការពារទៅតាមមូលហេតុនៃការលុបចោលកិច្ចសន្យារបស់អ្នកមានសិទ្ធិលុបចោលកិច្ចសន្យារវាងភាគីម្ខាងទៀតនៃកិច្ចសន្យា។ ការការពារតតិយជនធ្វើឡើងតាមរយៈបញ្ញត្តិដែលមានចែងនៅក្នុងករណីមានវិការៈក្នុងការបង្ហាញឆន្ទៈ និងទៅតាមបទបញ្ញត្តិដាច់ដោយឡែកក្នុងករណីអសមត្ថភាពខាងឆន្ទៈ ឬ ត្រូវបានកម្រិតសម្តភាព។

#### ៣.២.១.១.ករណីវិការៈនៃការបង្ហាញឆន្ទៈ

##### ក. ករណីភាន់ច្រឡំ ការឆបោក ពត៌មានមិនពិត ការរំលោភលើស្ថានភាព

ករណីដែលមានការលុបចោលដោយការភាន់ច្រឡំ ការឆបោក ពត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព តតិយជនដែលសុចរិត និងគ្មានកំហុសត្រូវបានការពារ។ ពោលគឺ ការលុបចោលកិច្ចសន្យារបស់អ្នកដែលមានសិទ្ធិលុបចោល មិនមានអានុភាពចំពោះតតិយជនឡើយ។ លក្ខខណ្ឌដែលតតិយជនត្រូវទទួលបានការការពារតាមរយៈ ការភាន់ច្រឡំ ការឆបោក ពត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព៖

- តតិយជនត្រូវជាជនសុចរិត គឺតតិយជនដែលមិនបានដឹងអំពីមូលហេតុនៃការលុបចោល ដូចជាមិនដឹងអំពីការភាន់ច្រឡំ ការឆបោក ការផ្តល់ពត៌មានមិនពិត ឬ ការរំលោភលើស្ថានភាព។
- តតិយជនគ្មានកំហុស គឺតតិយជនដែលគ្មានកំហុស ជាតតិយជនដែលបានធ្វើសកម្មភាពចាំបាច់ដូចជាស្រាវជ្រាវព័ត៌មាន យ៉ាងណាក៏ដោយក៏តតិយជននៅតែមិនដឹងអំពីមូលហេតុនៃការលុបចោល។

ដូច្នោះ អ្នកមានសិទ្ធិលុបចោល មិនអាចអះអាងការលុបចោលចំពោះតតិយជនបានទេ។

## ខ.ករណីគម្រាមកំហែង និងកេងយកចំណេញហួសហេតុ

ករណីដែលមានការលុបចោលដោយសារតែ ការគម្រាមកំហែង អំពើកេងយកចំណេញហួសហេតុ តតិយជនមិនត្រូវបានការពារទេ ទោះបីជាតតិយជននោះជាជនសុចរិត និងគ្មានកំហុសក៏ដោយ។ ដោយសារម្ចាស់សិទ្ធិពិតប្រាកដមិនមានកំហុសក្នុងវិការៈ ហេតុនេះការការពារម្ចាស់សិទ្ធិពិតប្រាកដមានភាពចាំបាច់។[74] ប៉ុន្តែតតិយជនក្នុងការលុបចោលដោយការគម្រាមគំហែង និងការកេងយកចំណេញហួសហេតុ អាចការពារនូវផលប្រយោជន៍របស់ខ្លួនដោយប្រើបញ្ញត្តិ ការធ្វើលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលវត្ថុ។ អ្នកដែលទទួលបានការផ្ទេរការកាប់កាន់នូវចលនវត្ថុ ដោយកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ហើយដោយសុចរិត និងគ្មានកំហុស ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុនោះ ទោះបីជាអនុប្បទាយីគ្មានកម្មសិទ្ធិលើអចលនវត្ថុនោះក៏ដោយប៉ុន្តែបញ្ញត្តិនេះមិនអាចយកមកអនុវត្តឡើយ ចំពោះករណីដែលអនុប្បទាយីនៅតែបន្តការកាន់កាប់ដោយចំពោះ[75] ។ លក្ខខណ្ឌដែលត្រូវការពារតតិយជនមានដូចជា៖

- កិច្ចសន្យាអនុប្បទានកម្មសិទ្ធិមានសុពលភាព គឺជាកិច្ចសន្យាដែលចាំបាច់មានសុពលភាព ព្រោះលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិ គឺជាការសង្គ្រោះសម្រាប់ករណីអនុប្បទាយីមិនមានកម្មសិទ្ធិហើយបានធ្វើកិច្ចសន្យាអនុប្បទាន ដូច្នោះគួរតែត្រូវការពារតតិយជនដោយបានធ្វើលទ្ធកម្មកម្មសិទ្ធិដោយសុចរិត។
- តតិយជនសុចរិត និងគ្មានកំហុស តាមមាត្រា ២៣៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី អ្នកកាន់កាប់ត្រូវបានសន្មតថាកាន់កាប់ដោយសុចរិត តាមរយៈការសន្មតនេះ បុគ្គលណាមួយដែលកំពុងធ្វើការកាន់កាប់ដែលចង់អះអាងពីលទ្ធកម្មដោយសុចរិតលើចលនវត្ថុ មិនបាច់ធ្វើការអះអាងពីភាពសុចរិតទេពីព្រោះច្បាប់បានសន្មតរួចហើយថាជាអ្នកកាន់កាប់គឺសុចរិត ផ្ទុយទៅវិញ ក្រមរដ្ឋប្បវេណីមិនបានសន្មតថា អ្នកកាន់កាប់គ្មានកំហុស ដូច្នោះបុគ្គលណាមួយដែលចង់ធ្វើលទ្ធកម្មដោយសុចរិតលើចលនវត្ថុ ចាំបាច់ត្រូវបញ្ជាក់ពីភាពគ្មានកំហុស។[76]

[74] សៀវភៅ កម្រងមេរៀនវិភាគទានច្បាប់, ទំព័រ ១៨១, ឆ្នាំ២០១៨។

[75] មាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណី។

[76] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ១-៣, ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ភ្នំពេញ, ទំព័រ ៧៣, ២០១៧។

- តតិយជនបានកាន់កាប់ដោយចំពោះលើចលនវត្ថុនោះ ដើម្បីធ្វើលទ្ធកម្មលើកម្មសិទ្ធិលើចលនវត្ថុ ដោយសុចរិតបាន ចាំបាច់ត្រូវតែទទួលបានការចាប់ផ្តើមការកាន់កាប់ តាមរយៈការប្រគល់ជាក់ស្តែង ការប្តូរលក្ខខណៈនៃការកាប់កាន់ ការប្រគល់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជា។[77]

### ៣.២.១.២.ករណីខ្វះសមត្ថភាពខាងឆន្ទៈ ឬ អសមត្ថភាព

ករណីដែលមានការលុបចោលដោយ មូលហេតុអសមត្ថភាព តតិយជនមិនត្រូវបានការពារឡើយ ព្រោះការលុបចោលដោយសារ អ្នកបង្ហាញឆន្ទៈអសមត្ថភាពខាងឆន្ទៈ ឬត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព អាចអះអាងចំពោះជនទាំងអស់ ហេតុនេះតតិយជនក្នុងករណីនេះមិនត្រូវបានការពារទេ។[78] ប៉ុន្តែអាចបកស្រាយប្រើប្រាស់នូវការធ្វើលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ ទោះបីជាអ្នកផ្ទេរចលនវត្ថុមានសិទ្ធិ ឬ គ្មានសិទ្ធិលើចលនវត្ថុក៏ដោយ។

ម៉្យាងទៀត ក៏អាចការពារតតិយជនបាន ទោះបីជាតតិយជនមានកំហុស ឬ ទុច្ចរិតក៏ដោយ តាមរយៈការបង្ហាញថា ជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោកដើម្បីឲ្យគេជឿជាក់ថាជាសមត្ថជន។[79] ក្នុងករណីដែលជនត្រូវបានកម្រិតសមត្ថភាពបានប្រើវិធីឆបោក តាមរយៈការបង្ហាញលិខិតក្លែងអាយុ ឬភូតកុហកថាខ្លួនបានទទួលការយល់ព្រមពីជនដែលមានសិទ្ធិផ្តល់ការយល់ព្រម ហើយបានបង្ហាញលិខិតយល់ព្រមក្លែងដល់ភាគីម្ខាងនៃកិច្ចសន្យា ជនដែលត្រូវបានកម្រិតសមត្ថភាពមិនត្រូវបានការពារទេ ដូច្នោះជនដែលត្រូវបានកម្រិតសមត្ថភាព ឬ ជនដែលមានសិទ្ធិផ្តល់ការយល់ព្រមលើសកម្មភាព មិនទទួលស្គាល់ឲ្យលុបចោលកិច្ចសន្យាទេ ហើយក៏មិនអាចអះអាងចំពោះតតិយជនបានដែរ។

### ៣.២.២.តតិយជនក្រោយការលុបចោល

តតិយជនក្រោយការលុបចោល ជាតតិយជនដែលបានទទួលសិទ្ធិបន្តពីភាគីម្ខាងទៀត ក្រោយការលុបចោលរបស់អ្នកមានសិទ្ធិលុបចោលកិច្ចសន្យា។ ពោលគឺ តតិយជនប្រភេទនេះទទួលបានការប្រគល់សិទ្ធិពីបុគ្គលដែលគ្មានសិទ្ធិចំពោះតាវកាលិកឡើយ។

តតិយជនក្រោយការលុបចោលកិច្ចសន្យា ទទួលរងការខូចខាតដោយសារតែចុះកិច្ចសន្យាជាមួយជនដែលគ្មានសិទ្ធិ មិនមែនដោយសារតែអានុភាពប្រតិសកម្មនៃការលុបចោលនោះទេ។ ការការពារតតិយជន

---

[77] មាត្រា ២២៩ នៃក្រមរដ្ឋប្បវេណី។

[78] សៀវភៅ កម្រងមេរៀនវិភាគទានច្បាប់, ទំព័រ ១៦៣, ឆ្នាំ២០១៨។

[79] មាត្រា ៣៣ នៃក្រមរដ្ឋប្បវេណី។

ក្រោយការលុបចោលកិច្ចសន្យា ត្រូវបានការពារតាមរយៈបញ្ញត្តិដោយឡែកស្តីការធ្វើលទ្ធកម្មសុចរិតលើចលនវត្ថុ ម៉្យាងទៀតចំពោះករណីអចលវត្ថុវិញក៏អាចការពារតតិយជនក្រោយការលុបចោល តាមបញ្ញត្តិមាត្រា ៣៦៤ កថាខណ្ឌ៤ នៃក្រមរដ្ឋប្បវេណីក៏បានដែរ ព្រោះបញ្ញត្តិនេះបានចែងការពារតតិយជន ដោយមិនបែងចែកតតិយជនមុន ឬក្រោយការលុបចោលទេ ហើយមិនតែប៉ុណ្ណោះមានវិធីសាស្ត្រពីរយ៉ាងទៀត គឺលក្ខខណ្ឌតតាំង និងការអនុវត្តប្រដូចដូចមាត្រា៣៥៣ កថាខណ្ឌទី២។

### ៣.២.២.១. ករណីចលនវត្ថុ

យើងអាចការពារតតិយជនដោយប្រើលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិចលនវត្ថុ ដូចករណីការគម្រាមកំហែង និង ការកេងចំណេញហួសហេតុ។ លក្ខខណ្ឌដែលត្រូវការពារមានដូចជា៖

- កិច្ចសន្យាអនុប្បទានកម្មសិទ្ធិមានសុពលភាព គឺជាកិច្ចសន្យាដែលចាំបាច់មានសុពលភាព ព្រោះលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិ គឺជាការសង្គ្រោះសម្រាប់ករណីអនុប្បទាយីមិនមានកម្មសិទ្ធិហើយបានធ្វើកិច្ចសន្យាអនុប្បទាន ដូច្នោះត្រូវតែការពារតតិយជនដោយបានធ្វើលទ្ធកម្មកម្មសិទ្ធិដោយសុចរិត។
- តតិយជនសុចរិត និងគ្មានកំហុស តាមមាត្រា ២៣៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី អ្នកកាន់កាប់ត្រូវបានសន្មតថាកាន់កាប់ដោយសុចរិត តាមរយៈការសន្មតនេះ បុគ្គលណាមួយដែលកំពុងធ្វើការកាន់កាប់ដែលចង់អះអាងពីលទ្ធកម្មដោយសុចរិតលើចលនវត្ថុ មិនបាច់ធ្វើការអះអាងពីភាពសុចរិតទេ ពីព្រោះច្បាប់បានសន្មតរួចហើយថាជាអ្នកកាន់កាប់គឺសុចរិត ផ្ទុយទៅវិញ ក្រមដ្ឋប្បវេណីមិនបានសន្មតថា អ្នកកាន់កាប់គ្មានកំហុស ដូច្នោះបុគ្គលណាមួយដែលចង់ធ្វើលទ្ធកម្មដោយសុចរិតលើចលនវត្ថុ ចាំបាច់ត្រូវបញ្ជាក់ពីភាពគ្មានកំហុស។[80]
- តតិយជនបានកាន់កាប់ដោយចំពោះលើចលនវត្ថុនោះ ដើម្បីធ្វើលទ្ធកម្មលើកម្មសិទ្ធិលើចលនវត្ថុដោយសុចរិតបាន ចាំបាច់ត្រូវតែទទួលបានការចាប់ផ្ដើមការកាន់កាប់ តាមរយៈការប្រគល់ជាក់ស្តែង ការប្តូរលក្ខខណៈនៃការកាប់កាន់ ការប្រគល់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជា។

[80] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ១-៣, ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ភ្នំពេញ, ទំព័រ ៧៣, ២០១៧។

### ៣.២.២.២.ករណីអចលនវត្ថុ

មិនមានមាត្រាណាមួយដែលបានចែងការពារតតិយជនក្រោយការលុបចោលចំពោះករណីអចលនវត្ថុ ដូចករណីចលវត្ថុទេ។ ប៉ុន្តែមានទស្សនៈចំនួន ៣ ដែលបានលើកឡើងបកស្រាយដើម្បីការពារតតិយជនក្រោយការលុបចោល៖

**+ទស្សនៈទី១ តតិយជនក្រោយការលុបចោលក៏ដូចជាតតិយជនមុនការលុបចោល**

នៅក្នុងក្រមរដ្ឋប្បវេណី មិនបានបែងចែកតតិយជនជាពីរប្រភេទទេ គ្រាន់តែបានឲ្យនិយមន័យនៃតតិយជនតែប៉ុណ្ណោះ នោះគេអាចបកស្រាយបានថាតតិយជនក្រោយការលុបចោលក៏ដូចជាតតិយមុនការលុបចោលដែរ បើតតិយជននោះសុចរិត និងគ្មានកំហុស ចំពោះករណីការភាន់ច្រឡំ ការឆបោក ការគម្រាមកំហែង និងការរំលោភលើស្ថានភាព អាចប្រើបញ្ញត្តិនេះការពាតតិយជនមុនការលុបចោលបានដូចគ្នា។

**+ទស្សនៈទី២ អនុប្បទានត្រួតគ្នា ឬ លក្ខខណ្ឌតតាំង**

អនុប្បទាន ជាការផ្ទេរសិទ្ធិ ឬ ទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ ដែលជាអនុប្បទាយីទៅឲ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក។[81]

លក្ខខណ្ឌតតាំង ជាលក្ខខណ្ឌដែលត្រូវបំពេញ ដើម្បីឲ្យអានុភាពតាមផ្លូវច្បាប់នោះអាចអះអាងចំពោះតតិយជនបាន។[82] ការតតាំង ជាប្រព័ន្ធមួយដែលក្រមរដ្ឋប្បវេណីបានបង្កើតឡើងក្នុងគោលបំណងដើម្បីការពារសុវត្ថិភាពខាងជំនួញរបស់បុគ្គលឯកជន ដើម្បីឲ្យម្ចាស់កម្មសិទ្ធិអាចធ្វើការបង្ហាញទៅកាន់សាធារណៈ ថាខ្លួនមានកម្មសិទ្ធិពិតប្រាកដទៅលើវត្ថុនោះ។ ដោយសារតែសិទ្ធិប្រត្យក្ស មានលក្ខណៈដាច់ខាត និងផ្តាច់មុខ ដែលអាចអះអាងចំពោះគ្រប់បុគ្គល[83] ហើយមិនអាចបង្កើតជាន់គ្នាបាន ដូចនេះហើយការបង្ហាញជាសាធារណៈមានពិតជាមានសារៈសំខាន់ណាស់ សម្រាប់ឲ្យសាធារណជនបានដឹងលឺ។

នៅពេលដែលកិច្ចសន្យាមួយត្រូវបានលុបចោល ភាគីម្ខាងទៀតនៃការលុបចោលមានករណីយកិច្ចផ្ទេរនូវអចលនវត្ថុទៅឲ្យអ្នកលុបចោល ហើយទន្ទឹមគ្នាប្រសិនបើភាគីម្ខាងទៀតនៃការលុបចោលបានលក់ ឬ បង្កើតទំនាក់ទំនងផ្សេងៗ ភាគីម្ខាងទៀតនៃការលុបចោលក៏ត្រូវមាន ករណីយកិច្ចផ្ទេរនូវអចលនវត្ថុដដែលឲ្យទៅតតិយជនផងដែរ។ ពោល គឺជាការផ្ទេរនូវអចលនវត្ថុតែមួយឲ្យទៅបុគ្គលពីរនាក់ផ្សេងគ្នា ដែរលនេះគេហៅថា “*អនុប្បទានត្រួតគ្នា*” ។

[81] សន្ទានុក្រម ផ្នែករដ្ឋប្បវេណី ចំណុច១៨៩។

[82] សៀវភៅ កម្រងមេរៀនវិភាគទានច្បាប់, ទំព័រ ១៨៦, ឆ្នាំ២០១៨។

[83] មាត្រា ១៣៥ នៃក្រមរដ្ឋប្បវេណី។

ដើម្បីការពារតតិយជនក្នុងករណីអនុប្បទានត្រួតគ្នា គេប្រើប្រាស់បញ្ញត្តិស្តីការចុះបញ្ជីអចលវត្ថុ ដែលមានចែងក្នុងមាត្រា ១៣៤ និងមាត្រា ១៣៥ នៃក្រមរដ្ឋប្បវេណី។ មានន័យថា ប្រសិនបើតតិយបានចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលវត្ថុ បានមុនអ្នកលុបចោលកិច្ចសន្យា តតិយជននឹងត្រូវបានការពារដោយផ្អែកលើកម្មសិទ្ធិ ដោយមិនបានកំណត់ថាតតិយជនសុចរិត ឬ ក៏ទុច្ចរិតទេ។ ដូច្នោះ បើអនុលោមតាមបញ្ញត្តិ ទោះបីជាតតិយជនជាជនទុច្ចរិតក៏ដោយក៏បានការពារផងដែរ។

ប៉ុន្តែក៏មានការបកស្រាយថា តតិយជនដែលកំណត់ក្នុងមាត្រា១៣៤ នៃក្រមរដ្ឋប្បវេណី គឺសំដៅទៅលើតែ តតិយសុចរិតនិ ងគ្មានកំហុស ឬ ក៏តតិយជនដែលសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរផងដែរ[84] ដែលការបកស្រាយបែបនេះគឺស្របទៅនឹងគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ ដែលមានចែងក្នុងមាត្រា ៥ នៃក្រមរដ្ឋប្បវេណី។

**+ទស្សនៈទី៣ បកស្រាយប្រដូចទៅនឹងការបង្ហាញឆន្ទៈមិនពិត**

កិច្ចសន្យាដែលធ្វើឡើងដោយការបង្ហាញឆន្ទៈមិនពិត ត្រូវចាត់ទុកថាមោឃៈ។[85] កិច្ចសន្យាដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិត រវាងភាគី ដោយបង្ហាញឆន្ទៈក្លែងក្លាយ។ ភាគីក្នុងន័យនេះ សំដៅដល់អ្នកលុបចោលកិច្ចសន្យា និងភាគីម្ខាងទៀតនៃការលុបចោល។

កិច្ចសន្យាដែលធ្វើឡើងដោយការបង្ហាញឆន្ទៈមិនពិត ដើម្បីអាចអះអាងពីមោឃភាពបាន ត្រូវគោរពទៅតាមលក្ខខណ្ឌ បី គឺ៖

- មានអត្ថិភាពនៃរូបភាពខាងក្រៅមិនពិត៖ រូបភាពមិនពិតមួយត្រូវបានបង្កើតឡើងដោយអ្នកលុបចោលកិច្ចសន្យា និងភាគីម្ខាងទៀត ដោយកម្មសិទ្ធិជារបស់អ្នកលុបចោល ប៉ុន្តែសិទ្ធិ និងព័ត៌មានដែលមាននៅក្នុងគោលបញ្ជីសុរិយោដី ជារបស់ភាគីម្ខាងទៀត។
- អ្នកមានសិទ្ធិលុបចោលជាម្ចាស់សិទ្ធិពិតប្រាកដមានកំហុសចំពោះការបង្កើតរូបភាពខាងក្រៅមិនពិត៖ អ្នកលុបចោលមានកំហុសដោយមិនបានលុបចោលភ្លាមៗនូវរូបភាពខាងក្រៅមិនពិត។
- ចាំបាច់ត្រូវការពារតតិយជនដែលបានធ្វើពាណិជ្ជកម្មដោយជឿជាក់លើរូបភាពខាងក្រៅមិនពិត៖ អ្នកមានសិទ្ធិលុបចោល និងភាគីម្ខាងទៀតបានឃុបឃិតគ្នា បង្កើតនូវរូបភាពមិនពិត ធ្វើឲ្យតតិយជន ព្រមទាំងសាធារណៈជន មានការជឿជាក់លើរូបភាពនេះ។

[84] មេរៀនភាគ ១ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ២៨, ២០១៥។

[85] មាត្រា ៣៥៣ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី។

គោលគំនិតនៃការបង្ហាញឆន្ទៈ គឺការពារចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ជាជាងភាគីនៃកិច្ចសន្យានៅក្នុងការលុបចោលលើកលែងតែតតិយនោះជាជនទុច្ចរិត ឬ មិនបានដឹងអំពីការបង្ហាញឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ។ [86] មានន័យថាប្រសិនបើភាគីនៃកិច្ចសន្យាដោយការបង្ហាញឆន្ទៈមិនពិតចង់អះអាងចំពោះតតិយជន ភាគីត្រូវទទួលបន្ទុកបញ្ជាក់ថា តតិយជននោះទុច្ចរិត ឬ មានកំហុសធ្ងន់ធ្ងរ។

[86] មេរៀនភាគ ២ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ក្រុមការងារក្រសួងយុត្តិធម៌, ភ្នំពេញ, ទំព័រ ៣៦, ២០១៦។

# សេចក្តីសន្និដ្ឋាន

ផ្អែកទៅតាមរយៈការសិក្សាស្រាវជ្រាវ ព្រមទាំងការបកស្រាយយ៉ាងក្បោះក្បាយមកនេះ ទាក់ទងទៅនឹងប្រធានបទ **ការលុបចោលកិច្ចសន្យា** វាពិតជាមានសារៈក្នុងការដែលភាគីនៃកិច្ចសន្យាចង់បដិសេធការអនុវត្តកិច្ចសន្យាដោយសារកិច្ចសន្យាដែលបង្កើតឡើងដោយមានមូលហេតុនៃការលុបចោល។ នៅក្នុងសង្គមបច្ចុប្បន្នការបង្កើតកិច្ចសន្យាគឺកើតមានជារៀងរាល់ថ្ងៃ ទន្ទឹមនឹងនោះដែរការបង្កើតកិច្ចសន្យាទាំងអស់នេះមាន កិច្ចសន្យាខ្លះគឺបង្កើតឡើង ជនដែលខ្វះសមត្ថភាពខាងឆន្ទៈ ជនដែលត្រូវបានកម្រិតសមត្ថភាពធ្វើឡើង ដូច្នេះហើយទើបក្រមរដ្ឋប្បវេណីបញ្ញតិថា កិច្ចសន្យាដែលបង្កើតឡើងដោយជនទាំងនេះអាចលុបចោលបាន ដើម្បីការពារនូវផលប្រយោជន៍របស់ពួកគេ ព្រោះដោយសារតែគម្លាតខុសគ្នា និងឆន្ទៈនៃការគិតពិចារណាពួកគេទាំងនោះនៅមានកម្រិត។ ម៉្យាងទៀតកិច្ចសន្យាដែលកើតចេញពីការបង្ហាញឆន្ទៈមិនពិតរបស់ភាគីនៃកិច្ចសន្យាមានដូច ការភាន់ច្រឡំ ការឆបោក ពត៌មានមិនពិត អំពើកេងចំណេញហួសហេតុ ការរំលោភលើស្ថានភាព ក៏ជាមូលហេតុនៃការលុបចោលផងដែរ ព្រោះកិច្ចសន្យានេះមិនបានកើតចេញពីឆន្ទៈផ្ទាល់របស់ភាគីនៃកិច្ចសន្យា ហើយបើទទួលស្គាល់នូវកិច្ចសន្យាបែបនេះ ហាក់ដូចជាគាំទ្រនូវការបង្កើតកិច្ចសន្យាដែលមិនស្របទៅតាមឆន្ទៈរបស់ភាគីនៃកិច្ចសន្យា ព្រមទាំងបង្កើតឲ្យគ្មានសមភាពនៃការធ្វើជំនួញ បាត់ទាំងធ្លាក់ចុះ និងបាត់បង់នូវតម្លៃសីលធម៌ក្នុងសង្គមផងដែរ។

ទោះបីជាក្រមរដ្ឋប្បវេណី អនុញ្ញាតឲ្យកិច្ចសន្យាដែលមានមូលហេតុនៃការលុបចោលអាចលុបចោលបានប្រាកដមែន ប៉ុន្តែដោយសារតែការលុបចោលកិច្ចសន្យានេះធ្វើឲ្យប៉ះពាល់ផងដែរដល់ផលប្រយោជន៍ភាគីម្ខាងទៀត ទើបក្រមរដ្ឋប្បវេណីបានកំណត់យ៉ាងច្បាស់លាស់ពីអ្នកដែលមានសិទ្ធិលុបចោលកិច្ចសន្យា ដែលខុសគ្នាពីមោឃភាព ព្រោះមោឃភាពគឺជាការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់សង្គម ហើយជនណាក៏អាចអះអាងអំពីមោឃភាពបានដែរ។ បន្ថែមពីលើនេះដែរ កិច្ចសន្យាដែលមានមូលហេតុនៃការលុបចោលអ្នកដែលមានសិទ្ធិលុបចោល គឺអាចផ្តល់សច្ចានុមតិនៃកិច្ចសន្យានោះបាន ពោលគឺទទួលស្គាល់អានុភាពជាស្ថានពរនៃកិច្ចសន្យានោះ ព្រោះកិច្ចសន្យាដែលមានមូលហេតុនៃការលុបចោល ក៏ជាកិច្ចសន្យាមួយដែលមានសុពលភាពដែរ ដរាបណាអ្នកដែលមានសិទ្ធិលុបចោលមិនលលុបចោលកិច្ចសន្យានោះ។ ការដែលទទួលស្គាល់សុពលភាពកិច្ចសន្យាបែបនេះ គឺដោយសារតែការគោរពស្វ័យភាពនៃបុគ្គលឯកជន ដោយរដ្ឋមិនធ្វើការជ្រៀតជ្រែកទៅក្នុងទំនាក់ទំនងឯកជន។ មិនត្រឹមតែប៉ុណ្ណោះទេ ដើម្បីធានាឲ្យបាននូវសមភាព និងនិរន្តភាពដោយមិនធ្វើការការពារតែម្ខាងទៅលើតែអ្នកដែលមានសិទ្ធិលុបចោលកិច្ចសន្យា ឬ ផ្តល់សច្ចានុមតិ ភាគីម្ខាងទៀតនៃកិច្ចសន្យាគឺអាចដាស់តឿ ភាគីដែលមានសិទ្ធិលុបចោលឲ្យផ្តល់ ឬ មិនផ្តល់សច្ចានុមតិ ហើយក៏មានការ

កំណត់អាជ្ញាយុកាលសម្រាប់ការរំលត់សិទ្ធិលុបចោលផងដែរ។ ការកំណត់នូវអាជ្ញាយុកាលសម្រាប់ការរលត់សិទ្ធិលុបចោលនេះ គឺដើម្បីភាគីដែលមានសិទ្ធិលុបចោលអនុវត្តសិទ្ធិលុបចោលរបស់ខ្លួនឲ្យបានកាន់តែឆាប់រហ័ស ចៀសវាងអូសបន្លាយដែលនាំឲ្យមានការខាតបង់ផលប្រយោជន៍របស់ភាគីម្ខាងទៀតនៃកិច្ចសន្យា។ ការលុបចោលកិច្ចសន្យា ឬផ្តល់សច្ចានុមតិមានលក្ខណៈងាយស្រួលដោយគ្រាន់តែភាគីដែលមានចង់លុបចោលកិច្ចសន្យា ជូនដំណឹងទៅភាគីម្ខាងទៀត ដើម្បីឲ្យគាត់បានដឹងពីការលុបចោលកិច្ចសន្យានេះ ហើយនៅពេលដែលកិច្ចសន្យាត្រូវបានលុបចោល នោះកិច្ចសន្យានឹងមានអានុភាពប្រតិសកម្ម បានន័យថាកិច្ចសន្យានោះត្រូវបានចាត់ទុកជាមោឃៈ ឬ គ្មានសុពលភាពតាំងពីដំបូងមកម្ល៉េះ ហើយភាគីនៃកិច្ចសន្យាមានករណីយកិច្ចត្រូវសងតាវកាលិកទៅវិញទៅមកតាមបញ្ញត្តិនៃសេចក្តីចម្រើនឥតហេតុ។ អ្វីដែលបង្កឲ្យមានភាពស្មុគស្មាញគឺនៅពេលដែលតាវកាលិកត្រូវបានផ្ទេរពីភាគីដែលមានករណីយកិច្ចសងតាវកាលិកទៅតតិយជន អានុភាពនៃការលុបចោលកិច្ចសន្យា ក៏កើតឡើងចំពោះតតិយជនផងដែរ។

ជាមួយនឹងការរៀបរាប់បញ្ហាខាងលើនេះ ធ្វើឲ្យយើងបានដឹងថា ការលុបចោលកិច្ចសន្យាគឺជាបច្ចេកទេសមួយដែលប្រើសម្រាប់បដិសេធការអនុវត្តកិច្ចសន្យា ប៉ុន្តែដោយសារតែប្រជាពលរដ្ឋយើងមិនទាន់មានចំណេះដឹងទូលំទូលាយ ក៏ដូចជាការយល់ដឹងពាក់ព័ន្ធទៅនឹងការលុបចោលកិច្ចសន្យា ធ្វើឲ្យពួកគាត់បានបាត់បង់នូវផលប្រយោជន៍ជាច្រើនតាមរយៈការបង្កើតកិច្ចសន្យា ដែលធ្វើឲ្យខាតបង់ដល់មុខជំនួញរបស់គាត់។ នេះសបញ្ជាក់ឲ្យបានដឹងថាប្រជាពលរដ្ឋមានចំណេះតិចតួចណាស់ ជាពិសេសខាងផ្នែកច្បាប់ ដោយពួកគាត់ភាគច្រើនអនុវត្តតែវិធានទំនៀមទំលាប់តាមយល់ឃើញដោយមិនមានមូលដ្ឋានច្បាស់លាស់ សម្រាប់ការប្រកបកិច្ចការជំនួញមួយប្រកដោយសមភាពនោះទេ។

ជារួមដោយសារតែប្រទេសកម្ពុជា ជាប្រទេសមួយដែលកំពុងតែអភិវឌ្ឍន៍ ហើយម៉្យាងទៀតដោយសារតែការយល់ដឹងរបស់ប្រជាពលរដ្ឋយើងនៅមានកម្រិត ធ្វើឲ្យការអនុវត្តច្បាប់នានាស្ថិតនៅក្នុងកម្រិតទាបមួយនៅឡើយ ដែលបង្កជាបញ្ហាប្រឈម ជាពិសេសគឺនីតិឯកជនដែលគ្រប់គ្រងជីវភាពរបស់នៅរបស់បុគ្គលឯកជនក្នុងជីវភាពប្រចាំថ្ងៃ។ នាងខ្ញុំសង្ឃឹមថាសារណាមួយនេះនឹងក្លាយទៅជាឯកសារមួយដ៏មានតម្លៃ ក្នុងការសិក្សាស្រាវជ្រាវដល់អ្នកសិក្សាស្រាវជ្រាវលើប្រធានបទនេះ ជាពិសេសគឺក្នុងការចែករំលែកចំណេះដឹងរបស់នាងខ្ញុំដែលមានទៅកាន់សាធារណជន។

# អនុសាសន៍

ដើម្បីជាការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងក្នុងប្រធានបទខាងលើ នាងខ្ញុំសំណូមពរដល់ស្ថានប័នរដ្ឋ ស្ថាប័នឯកជន រួមទាំងបុគ្គលដែលពាក់ព័ន្ធដូចខាងក្រោម៖

១.រដ្ឋាភិបាល៖ ពង្រឹងនូវការផ្សព្វផ្សាយ អប់រំពីច្បាប់នានាឲ្យបានទូលំទូលាយតាមរយៈការដាក់បញ្ចូលក្នុងប្រព័ន្ធអប់សម្រាប់សិស្សានុសិស្ស ផ្សព្វផ្សាយតាមរយៈប្រព័ន្ធអេឡិចត្រូនិច ទូរទស្សន៍ វិទ្យុ ទស្សនាវដ្ដីកាសែតសម្រាប់ប្រជាពលរដ្ឋទូទៅ ជាពិសេសបង្កើតនូវសិក្ខាសាលាសម្រាប់ផ្សព្វផ្សាយផ្ទាល់ដល់ប្រជាពលរដ្ឋដែលនៅតំបន់ដាច់ស្រយាលដែលមិនមានលទ្ធភាពអាចយល់ដឹងពីច្បាប់។

២.ក្រសួងយុត្តិធម៌៖ គប្បីចេញនីតិវិធីឲ្យមន្ត្រីដែលជាអ្នកអនុវត្តច្បាប់ យកចិត្តទុកដាក់ ពន្លឿនក្នុងការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ តាមរយៈការផ្ដល់មតិយោបល់ដល់ពួកគាត់ ឬ ផ្តល់មធ្យោបាយផ្សេងៗដើម្បីឲ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្បាស់ពីច្បាប់ ជាចំណែកក្នុងការចូលរួមអនុវត្តច្បាប់ផងដែរ។

៣.ស្ថាប័នតុលាការ៖ ពន្លឿននីតិវិធីនៃការដោះស្រាយវិវាទតាមផ្លូវតុលាការឲ្យបានលឿន និងមានប្រសិទ្ធិភាព ដើម្បីបុគ្គលដែលមានវិវាទអាចដោះស្រាយវិវាទរបស់ពួកគាត់បានកាន់តែឆាប់រហ័ស ព្រោះកាលណាតែនីតិវិធីតាមផ្លូវតុលាការមានរយៈយូរ ធ្វើឲ្យពួកគាត់ចំណាយពេលវេលា បាត់បង់ផលប្រយោជន៍ក្នុងការប្រកបចិញ្ចឹមជីវិត ដែលជាហេតុធ្វើឲ្យពួកគាត់មិនចង់ដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ។

៤.សិស្ស និស្សិត៖ គប្បីខិតខំប្រឹងប្រែងរៀនសូត្រ ស្រូបយកចំណេះវិជ្ជាផ្សេងៗ ព្រោះពួកគាត់សុទ្ធសឹងតែជាធនធានមនុស្ស ដែលសង្គមត្រូវការជាចាំបាច់ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិឲ្យរីកចម្រើន នាពេលអនាគត ជាពិសេសគួរមានការយល់ដឹងច្រើនអំពីច្បាប់ ទោះបីជាពួកគាត់ខ្លះមិនបានសិក្សាមហាវិទ្យាល័យនីតិសាស្ត្រពិតមែន ព្រោះដើម្បីកសាងប្រទេសជាតិឲ្យក្លាយជាប្រទេសនីតិរដ្ឋដ៏ពិតប្រាកដ។ ដូចនេះ សិស្ស និស្សិត គួរធ្វើជាគំរូក្នុងការគោរពច្បាប់ វៀងចាកការប្រព្រឹត្តបទល្មើស ជាជាងនេះទៅទៀតគឺត្រូវចែករំលែកពត៌មាន ក៏ដូចជាចំណេះដឹងទៅកាន់ក្រុមគ្រួសាររបស់ខ្លួន រួមទាំងអ្នកដទៃទៀត។

៥.ប្រជាពលរដ្ឋ៖ គប្បីចូលរួមក្នុងការលើកស្ទួយ និងអនុវត្តច្បាប់ដើម្បីឲ្យច្បាប់កាន់តែមានប្រសិទ្ធិភាព ជាពិសេសការប្រើប្រាស់ច្បាប់ជាគោលក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដូចជាការធ្វើជំនួញ អាជីវកម្ម ឬ របររកស៊ីចិញ្ចឹមជីវិតផ្សេងទៀត ព្រោះកាលណាអនុលោមតាមច្បាប់ មិនសូវមានហានិភ័យក្នុងការបាត់បង់ផលប្រយោជន៍ ឬការក្លែងបន្លំពីជនទុច្ចរិត ហើយច្បាប់អាចការពារផលប្រយោជន៍របស់ពួកគាត់បានយ៉ាងពេញលេញ។ ជាមួយគ្នានេះដែរ ប្រជាពលរដ្ឋគួរស្វែងរកពត៌មានពីច្បាប់នានា ដើម្បីឲ្យកាន់តែយល់ច្បាស់ពីច្បាប់ ព្រោះច្បាប់ជាធាតុសំខាន់ក្នុងការរស់នៅក្នុងសង្គមបច្ចុប្បន្ន។

## ឯកសារយោង


១.ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៣០, ០៨ ធ្នូ ២០០៧។

២.សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី,លេខ នស/រកម/០៥១១/00៧, ៣១ ឧសភា ២០១១។

៣.សៀវភៅកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១, ០៩ ធ្នូ ២០០៩។

៤.សៀវភៅកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២, ១០ មេសា ២០១០។

៥.សៀវភៅក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ របស់ក្រសួងយុត្តិធម៌, ធ្នូ ២០១៥។

៦.សៀវភៅក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ របស់ក្រសួងយុត្តិធម៌, វិច្ឆិកា ២០១៦។

៧.សៀវភៅកម្រងមេរៀន របស់វិភាគទានច្បាប់, ២០១៨។

៨.ឯកសារមេរៀន សញ្ញាណទូទៅនៃកាតព្វកិច្ច គង់សុភ័ក្រ្ត,២០១៨-២០១៩។

# ឧបសម្ព័ន្ធ

(ច្បាប់ ... )

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

S.S.C.C.

តុលាការកំពូល

# ដីកាកោះ

សំណុំរឿងរដ្ឋប្បវេណី

លេខ ...09...

ចុះថ្ងៃទី...10...ខែ...01...ឆ្នាំ២០២០

យើង ...ឌិត មុន្ទី... ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូល

បង្គាប់មកលោក-លោកស្រី...[illegible]... អាយុ...56... ឆ្នាំ មានមុខរបរ...

អាសយដ្ឋាន: ផ្ទះលេខ... ក្រុម/ផ្លូវ... ភូមិ...[illegible]... សង្កាត់/ឃុំ...[illegible]...

ខណ្ឌ/ស្រុក...[illegible]... រាជធានី/ខេត្ត...ភ្នំពេញ...

ឱ្យចូលខ្លួនមកកាន់តុលាការកំពូលនៅថ្ងៃទី...28...ខែ...កក្កដា...ឆ្នាំ...២០២០... វេលាម៉ោង...[illegible]...

ដើម្បីចូលរួមពីដំណើរការទាញហេតុផលដោយផ្ទាល់មាត់ទាក់ទងនឹងវិវាទអំពី...[illegible]...

...[illegible]...

"សាមីខ្លួនត្រូវអញ្ជើញមកអោយទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលមានទំនាក់ទំនងនឹងរឿងក្តីខាងលើមកជាមួយផង ប្រសិនបើមាន"។

[illegible]

ភ្នំពេញ ថ្ងៃទី...14...ខែ...កក្កដា...ឆ្នាំ...២០២០...

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ឌិត មុន្ទី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

(ទី ៤)

តុលាការកំពូល
***

សំណុំរឿង រដ្ឋប្បវេណី
លេខ ០១
ចុះថ្ងៃទី 10 ខែ 01 ឆ្នាំ 2020

# លិខិតអញ្ជើញ

មេធាវី [illegible]
012794847
098.600900

ប្រធាន [illegible]
ជំរាបមក [illegible]
ការបើកសវនាការរបស់តុលាការកំពូលដើម្បីជំនុំជំរះរឿង រដ្ឋប្បវេណី
ពីបណ្តឹងសាទុក្ខរបស់ឈ្មោះ [illegible] នឹងប្រព្រឹត្តទៅ
នៅថ្ងៃទី 28 ខែ កក្កដា ឆ្នាំ 2020 វេលាម៉ោង 8 (ព្រឹក [illegible])
ហេតុនេះសូមអញ្ជើញលោកទៅចូលរួមសវនាការក្នុងឋានៈជា [illegible] ។
ក្នុងករណីមានធុរៈ សូមលោកអោយដំណឹងមកតុលាការកំពូលជាបន្ទាន់ ។
[illegible]

ភ្នំពេញ , ថ្ងៃទី 14 ខែ កក្កដា ឆ្នាំ 2020
តុលាការកំពូល

ឌិត មុន្នី

(ដើម)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

S.S.C.C

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណី

លេខ 09

ចុះថ្ងៃទី 10 ខែ 01 ឆ្នាំ២០២០

# ដីកាកោះ

[illegible]

យើង ឌិត-មុន្ទី ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូល

បង្គាប់មកលោក-[illegible]

អាសយដ្ឋានៈ ផ្ទះលេខ..........ក្រុម/ផ្លូវ..............ភូមិ [illegible] សង្កាត់/ឃុំ [illegible]

ខណ្ឌ/ស្រុក [illegible] រាជធានី/ខេត្ត កំពត

ឱ្យចូលខ្លួនមកកាន់តុលាការកំពូលនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០២០ វេលាម៉ោង ៨ ព្រឹក ([illegible])

ដើម្បីចូលរួមពីដំណើរការទាញហេតុផលដោយផ្ទាល់មាត់ទាក់ទងនឹងវិវាទអំពី [illegible]

[illegible]

"សាមុីខ្លួនត្រូវអញ្ជើញមកអោយទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលមានទំនាក់ទំនងនឹងរឿងក្ដីខាងលើមក ជាមួយផង ប្រសិនបើមាន"។

[illegible]

ភ្នំពេញ,ថ្ងៃទី 14 ខែ កក្កដា ឆ្នាំ 2020

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ឌិត មុន្ទី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
***
សំណុំរឿង រដ្ឋប្បវេណី
លេខ ...09...
ចុះថ្ងៃទី 10 ខែ 01 ឆ្នាំ 2020

# លិខិតអញ្ជើញ

[illegible]

ប្រធាន តុលាការកំពូល
ជំរាបមក [illegible]
ការបើកសវនាការរបស់តុលាការកំពូលដើម្បីជំនុំជំរះរឿង រដ្ឋប្បវេណី
...........ពីបណ្តឹងសាទុក្ខរបស់ឈ្មោះ [illegible] នឹងប្រព្រឹត្តទៅ
នៅថ្ងៃទី 28 ខែ កក្កដា ឆ្នាំ 2020 វេលាម៉ោង 8 [illegible]
ហេតុនេះសូមអញ្ជើញលោកទៅចូលរួមសវនាការក្នុងឋានៈជា [illegible]
[illegible]
ក្នុងករណីមានធុរៈ សូមលោកអោយដំណឹងមកតុលាការកំពូលជាបន្ទាន់ ។
[illegible]
ភ្នំពេញ , ថ្ងៃទី 14 ខែ កក្កដា ឆ្នាំ 2020
តុលាការកំពូល